TKI0758

# សម្ភាសន៍ជាមួយឈ្មោះ អ៊ំ គុណ ភេទប្រុស អាយុ៩៨ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ ជាងដែកប្រចាំស្រុក

## រស់នៅភូមិអណ្តូងជ្រុង ឃុំកំពែង ស្រុកគិរីវង់ ខេត្តតាកែវ

## ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ ហ៊ិន សុផានី នឹង រី លក្ខិណា

០១:២៧:១០

៣៨ទំព័រ

ផានី : លោកគ្រូឈ្មោះអីដែរ?

គុណ : ខ្ញុំឈ្មោះ អ៊ំ គុណ ។

ផានី : ឆ្នាំហ្នឹងលោកគ្រូអាយុប៉ុន្មាន?

គុណ : អាយុ៩៨ឆ្នាំ ។

ផានី : លោកគ្រូមានស្រុកកំណើតនៅណាដែរ?

គុណ : នៅហ្នឹង នៅភូមិអណ្តូងជ្រុង ។

ផានី : ឃុំអីដែរ?

គុណ : ឃុំកំពែង ។

ផានី : ស្រុក?

គុណ : ស្រុកគិរីវង់ ខេត្តតាកែវ ។

ផានី : អញ្ចឹងសព្វថ្ងៃលោកគ្រូមានមុខរបរធ្វើអីដែរ?

គុណ : សព្វថ្ងៃនេះខ្ញុំជានាយកសាលាបឋមសិក្សាសុខ អាន អាំងស្វាយ ។

ផានី : លោកគ្រូរៀបចំគ្រួសារនៅឆ្នាំណាដែរ?

គុណ : ខ្ញុំរៀបចំគ្រួសារនៅឆ្នាំ១៩៧៩ ។

ផានី : លោកគ្រូមានកូនប៉ុន្មាននាក់?

គុណ : ខ្ញុំមានកូន៦នាក់ ។

ផានី : គ្រួសារលោកគ្រូឈ្មោះអីដែរ?

គុណ : ឈ្មោះ គន ស្រេម ។

ផានី : គាត់អាយុប៉ុន្មានហើយ?

គុណ ៖ អាយុ៥៣ឆ្នាំនេះ ។

ធានី ៖ គាត់មានស្រុកកំណើតនៅណាដែរ?

គុណ ៖ នៅហ្នឹងហ្នង កន្លែងកំណើតនៅទីហ្នឹងហ្នង ហើយឪពុកគាត់ហ្នឹងត្រូវប៉ុល ពត យក ទៅសម្លាប់ចោលដែរហ្នឹង ហើយចាំជម្រាបជូនតាមក្រោយតទៅទៀត ។

ធានី ៖ កូនលោកគ្រូទាំង៦នាក់ហ្នឹង ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

គុណ ៖ កូនខ្ញុំ៦នាក់ហ្នឹងគឺស្រី៥នាក់ ហើយប្រុស៣ ។

ធានី ៖ ឪពុកលោកគ្រូឈ្មោះអីគេដែរ?

គុណ ៖ ឪពុកខ្ញុំឈ្មោះអ៊ំ ពិន ។

ធានី ៖ ហើយចុះម្តាយ?

គុណ ៖ ម្តាយឈ្មោះ ណុប ណុន ។

ធានី ៖ គាត់រស់នៅទេ?

គុណ ៖ ឪពុកខ្ញុំស្លាប់នៅក្នុងរបបប្រល័យពូជសាសន៍ក្នុងឆ្នាំ៧៦ ដោយសារគាត់មានជម្ងឺ ហើយក្នុង នោះជីវភាពមិនបានគ្រប់គ្រាន់ ហើយអាហារហូបមិនបានគ្រប់គ្រាន់ទៀត ។

ធានី ៖ ចុះម្តាយលោកគ្រូវិញ?

គុណ ៖ ម្តាយខ្ញុំទើបតែស្លាប់បានមួយឆ្នាំកន្លះឆ្នាំនេះ ព្រះជន្មគាត់បាន៩៣ឆ្នាំ ។

ធានី ៖ លោកគ្រូរៀនសូត្របានដល់ណាដែរ?

គុណ ៖ ខ្ញុំបានរៀនដល់ថ្នាក់ទី៣ នៅអនុវិទ្យាល័យគិរីវង់ ។

ធានី ៖ ថ្នាក់ទី៣ នៅអនុវិទ្យាល័យគិរីវង់?

គុណ ៖ បាទ!

ធានី ៖ ទី៣យើងឥឡូវឬក៏?

គុណ ៖ ថ្នាក់ទី៣យើងឥឡូវវាស្មើនឹងថ្នាក់ទី៩ ។

ធានី ៖ អញ្ចឹងមានតែលោកគ្រូរៀនថ្នាក់ទី៩កាលសម័យនោះ?

គុណ ៖ បាទ! បើប្រៀបធៀបឥឡូវថ្នាក់ទី៩ ។

ធានី ៖ ហើយពេលដែលរៀនហ្នឹងម៉េចបានជាលោកគ្រូឈប់រៀន?

គុណ ៖ ដោយសារឆ្នាំហ្នឹងចូលឆ្នាំរដ្ឋប្រហារទៅ ដោយនៅតំបន់ហ្នឹងខ្ញុំអត់បានបន្ត អញ្ចឹងក៏សាលា ហ្នឹងក៏បិទ ដល់ពេលសាលាហ្នឹងបិទ គេទៅបើកនៅខេត្តតាកែវ អញ្ចឹងខ្ញុំអត់បានទៅបន្ត ចំណេះដឹងទេ ហើយខ្ញុំនៅរួមរស់ជាមួយឪពុកម្តាយ ហើយក៏នៅជាមួយគ្រួសារហ្នឹងមក

ហើយជំនេរពីហ្នឹងមកឆ្នាំ៧១ហ្នឹងខ្ញុំមិនដឹងទៅណា ហើយតំបន់ហ្នឹងគេនៅប្រទាញប្រទង់ខ្មែរក្រហមយប់ លន់ នល់ ថ្ងៃប៉ុន្តែ លន់ នល់ គិរីវង្ស ប៉ុន្តែតំបន់ហ្នឹងខ្មែរក្រហមអាចចូលលុកលុយបាន អញ្ចឹងខ្ញុំមិនអាចរំដោះបាន ហើយឪពុកម្ដាយខ្ញុំមានជីវភាពក្រីក្រ អញ្ចឹងក៏គាត់ឲ្យខ្ញុំបួស ព្រោះខ្លាចគេចាប់យកទៅធ្វើទាហានខ្មែរក្រហម ធ្វើឈ្លបធ្វើអីទៅ ។

ធានី : បួសនៅវត្តណាដែរលោកគ្រូ?

គុណ : បួសនៅវត្តកំពែង ឃុំកំពែង ។

ធានី : ហើយបន្ទាប់មកទៀតយ៉ាងម៉េចទៀតលោកគ្រូ?

គុណ : ក្រោយមកពេលដែលខ្ញុំបួសហ្នឹង សម័យនោះមុនដំបូងគឺមិនបញ្ហាអីទេ នៅមានជំនឿច្រើនណាស់លើពុទ្ធសាសនាយើង តែក្រោយមកគឺអង្គការគេ ពេលនោះគឺខ្មែរក្រហមបានសួរនាំ អញ្ចឹងអង្គការគេបានប្រជុំព្រះសង្ឃចុះដោះស្រាយខ្លួនឯង អញ្ចឹងសម័យនោះគឺព្រះសង្ឃគឺបង្ករបង្កើនផលដើម្បីយកផលិតផលហ្នឹងមកទប់ទល់ ហើយបិណ្ឌអញ្ចឹងខ្លះទៅ ហើយពេលនោះឯង បិណ្ឌហ្នឹងប្រជាជនយ៉ាប់ដែរ មានបាយរាងស្ដួច គាត់ចាប់ហើយពេលហ្នឹងព្រោះអត់បានធ្វើអី ហើយគេប្រមូលគោពពែអីដាក់រួម អញ្ចឹងបិណ្ឌហ្នឹងប្រជាជនខ្លះក៏គាត់បានដាក់ អញ្ចឹងព្រះសង្ឃនៅពេលនោះក៏លំបាកដែរ អញ្ចឹងដល់ឆ្នាំ១៩៧៤ អញ្ចឹងគេត្រូវកាត់អស់ហើយ អញ្ចឹងសម័យនោះនៅក្នុងឃុំកំពែងទាំងមូលមាន៦វត្ត អញ្ចឹងវត្តព្រៃវែងមួយចាប់លោកសម្លាប់អស់ហើយ អញ្ចឹងខ្ញុំក៏បានជំនុំជាមួយអធិការ ហើយខ្ញុំថាព្រះអង្គ បើថានេះសឹកទៅ ព្រោះយប់ឡើងគឺវាមកក្ដាប់ ឈ្លបគេមកស៊ើបអង្កេតក្រោមកុដ្ឋហ្នឹងរាល់យប់ ហើយចៃដន្យយប់មួយនោះខ្ញុំចុះបត់ជើង ឃើញវានៅអែបមាត់ទ្វា ដល់ហើយអត់ហ៊ានចុះដល់ក្រោយមកស្អែកឡើងគេហៅចៅអធិការទៅប្រជុំនៅវត្តព្រៃដើង ហើយគេលើកហេតុផលថា ព្រះសង្ឃកុំបាច់ព្រួយបារម្ភអី បើមានវិបត្តិអីមិនបាច់រត់ទៅណាទេ បើគ្មានរឿងហេតុអីពាក់ព័ន្ធផ្សេងៗទេកុំបាច់ព្រួយបារម្ភ អញ្ចឹងលោកមកវិញបានណែនាំលោកៗអញ្ចឹងហើយកុំភ្ញាក់ផ្អើលថាគេយកលោកវត្តនេះទៅសម្លាប់ ហើយលោកវត្តនេះខ្លាចគិតរករត់ទៅក្រោមទៅយួនទៅអីហ្នឹង ដល់ពេលនោះមានគំនិតអញ្ចឹងដែរ ព្រោះវាទាល់ច្រកដែរ អញ្ចឹងក្រោយមកក៏សម្រេចចិត្តទាំងអស់អង្គ ៦-៧អង្គសម្រេចចិត្តថាសឹក ពេលដែលសឹកហ្នឹងគឺចៅហ្វាយស្រុករបស់គេគឺ យាយបូ.. ។

ធានី : យាយបូ ហ្នឹងស្រី?

គុណ ៖ បាទ! យាយបូ ហ្នឹងស្រី តែមិនដឹងថាស្អីបូទេ គាត់មកលេងវត្តហ្នឹង ខ្ញុំហ្នឹងអ្នកនាំអាតថា លោកយាយអាត្មាគិតសុំសឹកហើយទាំងអស់គ្នាហ្នឹង ហើយគាត់សួរថាមែនអេ៎ ដល់ហើយខ្ញុំថាមែន គ្រាន់ថាមែនអញ្ចឹងក៏គាត់ឲ្យនិរសារបស់គាត់ហ្នឹងទៅយកសម្លៀកបំពាក់ខោអាវខ្មៅយកមកឲ្យលមើល លោកណាត្រូវតូចយកតូចទៅ លោកណាត្រូវធំយកធំទៅ អញ្ចឹងក៏បានសឹកទៅ ពេលដែលសឹកហ្នឹងគឺអត់បាននៅផ្ទះទាំងអស់គ្នាទេ សឹកភ្លាមគាត់យកទៅឲ្យគេនាំទៅកន្លែងគាត់ ហើយយកទៅកន្លែងគាត់គឺបំបែកគ្នាថា ចៅអធិការហ្នឹងគឺនៅកន្លែងគាត់ សឹកហើយហ្នឹង ឯខ្ញុំ៦នាក់ទៀតគេយកទៅដាក់កន្លែងចិញ្ចឹមជ្រូកនៅវត្តសុបិន្ត សុបិន្តយើងនៅស្រុកគិរីវង់ដែរ ។ ខ្ញុំនៅបានរយៈពេលចំនួន២ឆ្នាំចិញ្ចឹមជ្រូកកន្លែងនោះនៅវត្តហ្នឹងហ្នង ជាមួយប្រជាជនផ្សេងទៀត គ្នាប្រហែលជាជាង១០នាក់ អញ្ចឹងពេលចិញ្ចឹមជ្រូកបានអញ្ចឹង ពេលនោះខ្ញុំមានការវៃឆ្លាតដែរចេះធ្វើជាង ធ្វើរបងជ្រូកធ្វើអីអញ្ចឹងទៅ ធ្វើពីស៊ីម៉ងត៍អញ្ចឹងទៅ គាត់មើលឃើញខ្ញុំរាងចេះដឹង ក៏គាត់ជ្រើសរើសខ្ញុំឲ្យទៅរៀនធ្វើជាង ធ្វើជាងផលិតឆ្នាំងដែកយើងហ្នឹង ហើយនឹងផលិតផាលសម្រាប់ភ្ជួរស្រែ អញ្ចឹងក៏គាត់ហ្នឹងបានឲ្យខ្ញុំហ្នឹងទៅរៀននៅអគ្គការគេហ្នឹង បានឲ្យខ្ញុំទៅរៀននៅខេត្តតាកែវហ្នឹងបានរយៈពេល៣ខែ ទៅរៀនស្លូវឆ្នាំងខ្ទះហ្នឹង អញ្ចឹងពេលក្រោយមកក៏គាត់បានសរសេរសំបុត្រដើម្បីសុំឲ្យខ្ញុំហ្នឹងយកមកផ្តល់ចំណេះដឹងដល់មូលដ្ឋាន អញ្ចឹងខ្ញុំក៏ត្រលប់មកបានមកនៅចាក់ឆ្នាំងហ្នឹងវា៣-៤កន្លែង ទី១គឺនៅឃុំគោកព្រិច នៅវត្តចំបក់ ក្រោយចាក់ពីហ្នឹងមកបានរយៈពេលមួយឆ្នាំ នៅឆ្នាំ៧៦គេប្តូរទៅកន្លែងវត្តសុបិន្ត ខាងកើតហ្នឹងទៀត អញ្ចឹងដល់ពេលបានដល់ចុង៧៧ ចុង៧៧ហ្នឹងគេបញ្ជូនទៅគិរីវង់ ហើយពេលនោះឯងយើងមានរំដើបរំជួលនៅតាមព្រំដែន វៀតណាមធ្វើការ ហើយបានបុកចូលមក ហើយកាលនោះគឺខាងបូព៌ា ខាងស្វាយរៀងអីហ្នឹងគឺកាន់កាប់ដោយកងទ័ពយើងរំដោះខ្មែរក្រហមហ្នឹងណា៎ ប៉ុន្តែវានូវមានខ្មែរក្រហមវ៉ៃជាមួយវៀតណាមនៅគិរីវង់ដែរ អញ្ចឹងក្រោយមកខ្ញុំនៅចាក់នៅកន្លែងហ្នឹង ពេលហ្នឹងវៀតណាមបុកចូលខ្លាំង ព្រំដែនខាងត្បូងហ្នឹងគឺខាងភ្នំដិនយើង អញ្ចឹងពេលបុកមកឈាងនៅក្នុងស្រុកទាំងអស់ គឺចៅហ្វាយស្រុកហ្នឹងគេថាសុំឲ្យទៅជួយកងទ័ព កាន់កាំភ្លើងជួយកងទ័ពដេញវៀតណាមចេញពីស្រុក អញ្ចឹងពេលនោះមួយៗសុទ្ធតែយំហើយ ព្រោះមិនចេះកាន់កាំភ្លើង ធ្លាប់តែកាន់ញញួរកាន់ដែក អញ្ចឹងទៅកាលហ្នឹងមិនជាងដែកគ្នាជាង២០នាក់គឺទៅទាំងអស់គ្នា លើកលែងតែចាស់ៗទេដែលមិនអាចទៅបាន អញ្ចឹងចូលទៅដេញខ្មែរក្រហមជាមួយកងទ័ពហ្នឹងគឺបានតែគេឲ្យជួយរែកបាយ

យកចំណីអី ហើយចាំជួយសែនទ័ពដែលត្រូវរបួសហ្នឹង អញ្ចឹងពេលហ្នឹងក៏បានដេញកងទ័ពវៀតណាមចេញទៅឆ្នាំ១៩៧៨ ។

ផានី : ពេលហ្នឹងយើងដេញទៅ?

គុណ : បាទ! ក្រោយមកក្រោយគេដេញទៅបានរយៈពេលប៉ុន្មានខែ គឺកងកម្លាំងវៀតណាមរួមជាមួយកងទ័ពរណសិរ្សរួបរួមកម្ពុជាវ៉ៃបុកមក ដល់ពេលវ៉ៃបុកមកខ្ញុំក៏រត់ថយក្រោយដែរ ហើយរត់មកបានជួបជុំគ្រួសារ ដើរជាមួយគ្រួសារឪពុកម្ដាយមក ហើយបានគេចផុតរួច ។

ផានី : អញ្ចឹងខ្ញុំសុំសួរលោកគ្រូបកក្រោយបន្តិចថា កន្លែងពេលដែលលោកគ្រូទៅប្រជុំនៅ ពេលដែលលោកគ្រូបួសហ្នឹង គេហៅទៅប្រជុំហ្នឹង ប្រជុំជាមួយអ្នកណាគេដែរ?

គុណ : ពេលនោះគឺប្រជុំហ្នឹងច្រើនវត្តណាស់ វត្តទី១គឺវត្តសំខាន់ជាងគេគឺគេឲ្យ២អង្គ គឺខ្ញុំមួយហើយលោកមួយទៀតនៅភូមិខ្ញុំនេះដែរ ។

ផានី : គាត់ឈ្មោះអីគេ?

គុណ : ឈ្មោះម៉ក់ សុខន ។ អញ្ចឹងលោកនៅនេន ហើយខ្ញុំបានសឹក អញ្ចឹងឲ្យទៅប្រជុំនៅវត្តទួលផ្ដិក ទួលផ្ដិកហ្នឹងនៅខេត្តកំពត នៅខាងជើងដីវីរមៀលវត្តភ្នំហ្នឹង បៀតត្រពាំងអណ្ដើកហ្នឹង ដើរទៅគិតតែដើរទៅដេកមួយយប់ កាលហ្នឹងដើរឆ្ងាយ យើងដើរវាង ទៅនោះនៅដេកប្រជុំនៅហ្នឹង អញ្ចឹងក្នុងនោះពេលដែលប្រជុំនោះគឺមានតាជូ ចេត គេហៅតាជូ ចេត តែខ្ញុំមិនដឹងម៉េចទេគេហៅជូ ចេត អញ្ចឹង ហើយនឹង តាមុត គាត់ប្រធានតំបន់ ហើយក្នុងនោះព្រះសង្ឃខេត្តកំពត ខេត្តតាកែវយើងមកមូលបានមកមូលគ្នា គេទំនប់បំរុងចង្ហាន់ហ្នឹងរយៈពេលមួយអាទិត្យ ប្រជុំហ្នឹងរយៈពេលមួយអាទិត្យ អញ្ចឹងគេលើកហេតុផលពីជ័យជំនះរបស់ខ្មែរក្រហម អំពីរឲ្យព្រះសង្ឃហ្នឹងចេះពង្រឹងខ្លួន ចេះដោះស្រាយជីវភាពដោយខ្លួនឯង គេលើកឡើងអំពីអរិយទ្រព្យ៧ប្រការ ៧ប្រការបាលីយើងវាមាន គេមិនមែននិយាយតាមភាសាបាលីអី គេនិយាយដូងសុនំ គ្រាវសុនំ ស្រូវសុនំ អាសុនំៗហ្នឹងទ្រព្យហើយចង់ឲ្យបង្កបង្កើនផលតាំងពីដាំត្រាវ ដាំស្ពៃ ដាំដំឡូងដាំអី មិនមែនទ្រព្យអរិយតាមធម៌របស់ព្រះពុទ្ធទេ អញ្ចឹងនឹកឃើញដល់ហ្នឹងមិនដឹងគិតម៉េចទេ ទាំងធម្មយុត្ត ទាំងមហានិកាយប្រជុំមូលនៅនោះដែរ ។

ផានី : ហើយគេប្រជុំហ្នឹងដើម្បីកំណត់ពង្រឹងតែប៉ុណ្ណឹងទេ ឬក៏មានអីផ្សេងទៀត?

គុណ : គេពង្រើងប៉ុណ្ណឹង ហើយម្យ៉ាងទៀតគឺគេចង់អប់រំយើង បើអង្គការចង់សឹកចង់អីហ្នឹងគឺអង្គការទទួលចូលបម្រើជាតិដើម្បីរំដោះជាតិរំដោះអីអញ្ចឹងទៅ គេបំពាក់គោលនយោបាយច្រើនណាស់ ។

ធានី : កាលហ្នឹងសមាជិកដែលចូលរួមប្រជុំហ្នឹងមានប៉ុន្មាននាក់ដែរ?

គុណ : បើចំពោះព្រះសង្ឃរាប់រយអង្គ ៦សមាជិករបស់អង្គការគេហ្នឹងច្រើនណាស់ ចូលជាង២០នាក់ គេមកគ្នាគេ ប៉ុន្តែអ្នកដែលមានយោបល់អប់រំណែនាំហ្នឹងមានតាដូ ចេត ហ្នឹងនិយាយច្រើន ហើយតាមុត ហ្នឹងក៏និយាយច្រើនដែរ ហើយនឹងក្រុមគេហ្នឹង ។

ធានី : ចុះម៉េចបានជាលោកគ្រូដឹងថាគាត់ហ្នឹងឈ្មោះ ដូ ចេត?

គុណ : គាត់ប្រកាសហ្នង គាត់ប្រកាសឈ្មោះគាត់ ។

ធានី : ហើយតាមុត ហ្នឹងគាត់ស្អីគេមុត?

គុណ : មិនដឹងស្អី មុត ទេញតែគេហៅ មុតៗ ប្រធានតំបន់ ឥឡូវខ្ញុំភ្លេចបាត់ហើយ បើតាដូ ចេត នោះខ្ញុំចាំ ។

ធានី : គាត់ហ្នឹងជាអីដែរនៅហ្នឹង?

គុណ : គាហ្នឹងបែបជាប្រធានភូមិភាគហើយ ។

ធានី : ហើយបន្ទាប់មកទៀតពេលដែលលោកគ្រូថាចង់ផ្សឹកនៅឆ្នាំ៧៤ ហេតុអីបានជាលោកគ្រូចង់ផ្សឹក?

គុណ : ពេលនោះព្រះសង្ឃអស់ហើយ គេសម្លាប់អស់ហើយ នៅតែវត្តកំពែងមួយទេដែលមិនទាន់យកទៅអប់រំ យកទៅដាក់គុកដាក់អីហ្នឹង យកទៅអប់រំហើយដាក់គុកហ្នឹងមិនត្រូវឃុំឃាំងដើម្បីសួរចម្លើយយើងថាមានពាក់ព័ន្ធលោកវត្តនេះទេ លោកវត្តនោះទេ ចង់រត់ចុះទៅក្រោមទៅអីហ្នឹង អាហ្នឹងអញ្ចឹង អញ្ចឹងដោយមើលឃើញការអញ្ចឹង ហើយម្យ៉ាងទៀតទ្រព្យសម្បត្តិរបស់គាត់ហ្នឹងគឺគេតាមដាន យកទៅប្រគល់ឲ្យគេ យកទៅប្រគល់ឲ្យអង្គការ ហើយអញ្ចឹងខ្ញុំបួសក្រោយគឺបានផ្អាប់ចាន សម្ភារៈវត្តហ្នឹងក្រោមកុដិលោកជីកដាក់ជាងប៉ុណ្ណឹង ជាមួយចៅអធិការនឹងលោកនេនផ្សេងទៀត កប់ពាពង អញ្ចឹងពេលនោះគេមកសួររកអញ្ចឹងក៏គាស់ប្រគល់ជូនមេឃុំ កាលហ្នឹងមេឃុំគេ ឈ្មោះ ញ៉ែត តាញ៉ែតៗ ចំណាំប៉ុល ពត តាញ៉ែតហ្នឹងគឺប្រកាសហៅហើយ ហើយចាប់សម្លាប់ឪពុកក្មេកខ្ញុំអីហ្នឹង ហើយប្រជាជននៅក្នុងភូមិខ្ញុំហ្នឹង៤នាក់ស្លាប់មុំក្បែហ្នឹង អញ្ចឹងដល់ពេលមើលទៅឃើញមានការលំបាកអញ្ចឹងខ្ញុំមិនអាចនៅបានទេ បបួលលោកសឹកហើយ ។

ធានី : អញ្ចឹងកាលពេលដែល គាញៀត ហ្នឹងមកសួរនាំយកចានឆ្នាំងហ្នឹង..?

គុណ : បាទ! ពេលនោះគឺបានគាត់គាស់ឲ្យគេ កាលនៅលោកហ្នឹងណាំគាស់ឲ្យគេអស់ ។

ធានី : ចង់និយាយថាពេលហ្នឹងចាប់ផ្ដើមសម្លាប់មនុស្សនៅក្នុងភូមិ?

គុណ : ចាប់តាំងពីមុនមក មុនហ្នឹងមួយឆ្នាំពីរ ឪពុកក្មេកខ្ញុំស្លាប់នៅឆ្នាំ១៩៧៦ដែរ ដូចជា៧៥ បែកភ្នំពេញហើយបានមួយឆ្នាំ ប្រហែលជា៧៥ ខ្ញុំវាអត់ចាំដែរបង ព្រោះវាយូដែរ ខ្ញុំវាអត់ចាំ ខ្ញុំទើបតែការឆ្នាំ៧៩ហើយខ្ញុំចុះមក ហើយពេលដែលនៅបួសហ្នឹងមិនមែននេះទេ អញ្ចឹងពេលនោះគឺពួកទាហានបុកមកនៅនេះ ហើយគេជម្លៀសព្រះសង្ឃទៅឆ្ងាយស្រែក្នុងបាក់នឹមនៅបៀតត្រពាំងអណ្ដើកក្នុងខេត្តកំពត ព្រះសង្ឃមិតទៅហ្នឹងជាមួយប្រជាជនដែរ ដល់ពេលប្រជាជនចុះមកក៏ចុះមកជាមួយប្រជាជនដែរ អាហ្នឹងក្នុងឆ្នាំ៧៤យើងចុះមកហ្នឹង អាហ្នឹងដល់ពេលអញ្ចឹងទៅចាប់ផ្ដើមគឺងីងទៅ ហើយមានការដឹកប្រឡាយដឹកអី យកប្រជាជនទៅវៃចោល ខ្ញុំនឹកឃើញថាមានការលំបាកក្នុងការរស់នៅ សង្ឃពេលនោះឯងអត់មានអីទេបង អត់ទោសចុះចង្ហាន់មិនដែលគ្រប់គ្រាន់ទេ លែងគ្រប់គ្រាន់ហើយ អញ្ចឹងនឹកឃើញថាការសម្លាប់ហ្នឹងប្រហែលជាជិតដាមដល់លោកយើងទៀត ក្រែងលោលោកយើងមានការមន្ទិល ដល់ហើយបបួលលោកសឹកទៅ លោកក៏សម្រេចចិត្តថាសឹកពេលហ្នឹង ហើយក៏បានសម្រេចចិត្តសឹកហើយយកសម្លៀកបំពាក់យាយហ្នឹងមកសាក ហើយស្អែកឡើងសឹក ហើយដើរលាប្រជាជនមួយថ្ងៃល្ងាច លាតាមភូមិហ្នឹង យំអស់ហើយយាយតាអីហ្នឹង ។

ធានី : ហើយលោកគ្រូពេលលោកគ្រូសឹកថាមានគ្នា៧នាក់ ពួកគាត់មានឈ្មោះអីដែរ?

គុណ : បាទ! ទី១ឈ្មោះលោកគ្រូ អ៊ឹម កាន់ ហៅ ដុះ, ទី២គឺរូបខ្ញុំ, ទី៣គឺលោកម៉ក់ សុខន, ទី៤គឺសូ ឈាន, ទី៥គឺ វង ប៊ុន, ទី៦គឺ ញ៉ើក ហៅ សេង ហើយនឹងទី៧គឺនៅប្រាសាទមួយទៀតឈ្មោះ ដាត ។

ធានី : ហើយចុះមួយណាដែលគាត់ធ្វើជាចៅអធិការ?

គុណ : ហ្នឹង អ៊ឹម កាន់ ។ អញ្ចឹងពេលនោះគាត់យកទៅនៅកន្លែងគាត់ហ្នឹងគឺ ក្រោយមកគេឲ្យគាត់ហ្នឹងរៀនខាងសូរអំពូលថ្នាំ អញ្ចឹងយកមកកន្លែងសូរអំពូលថ្នាំហើយកន្លែងធ្វើដែកហ្នឹងបានមកមូលគ្នាជាមួយខ្ញុំហ្នឹងដែរ ។

ធានី : នៅពេលដំបូងពេលដែលថាសឹកហ្នឹង យាយបូ ហ្នឹងគាត់ឲ្យ?

គុណ : គាត់ឲ្យសម្លៀកបំពាក់ ។

ធានី ៖ គាត់ឲ្យសម្លៀកបំពាក់ ហើយឲ្យចៅអធិការទៅផ្សេង ហើយលោកគ្រូទៅផ្សេង?

គុណ ៖ បាទ! តែដល់ក្រោយមកគាត់ទៅដល់ហ្នឹង តួនាទីគាត់អត់ដឹងធ្វើអីទេ បែបគ្មានទេបើតាមមើលគ្មានធ្វើអីទេ គាត់អត់មានបានធ្វើការងារអីដើរទៅណាទៅណីទេ នៅចាំតែកន្លែងហ្នឹងគាត់អត់មានអីទេ ។

ធានី ៖ អាហ្នឹងនៅកន្លែងណាដែរលោកគ្រូ?

គុណ ៖ អាហ្នឹងនៅស្រុកគេ តែក្រោយមកបានគេបញ្ជូនគាត់មកកងចល័ត កងចល័តហ្នឹងគាត់ប្រហែលជាមានតួនាទីដឹកនាំមេក្រុមមេអីហ្នឹង ក្នុងការដឹកប្រឡាយ លើកទំនប់អីហ្នឹង គាត់អត់បានចូលបម្រើក្នុងជួរទ័ពទេ ព្រោះអត់នៅជាងដែកជាមួយខ្ញុំ ។

ធានី ៖ អញ្ចឹងលោកគ្រូដឹងទេ ថាហេតុអីគ្រាន់តែលោកគ្រូសុំហើយយាយបូ គាត់រៀបចំខោអាវឲ្យលោកគ្រូ?

គុណ ៖ ពេលនោះគេចង់ឲ្យតែលោកសឹកអស់ទេ គេត្រូវតែផ្សឹក តាមពិតលោកត្រូវអស់ហើយមិនត្រូវនៅទេ ប៉ុន្តែយើងសុំសឹកអញ្ចឹងហ្នឹងវាស្រួល កុំឲ្យគេមកផ្សឹកយើង ជៀសមិនរួចត្រូវតែអស់លោក ។

ធានី ៖ ហេតុអីលោកគ្រូ?

គុណ ៖ អញ្ចឹងបងស្រីដឹងហើយថា កាលសម័យខាងផ្នែកសាសនាគេមិនសូវជឿប៉ុន្មានទេ បើសិនណាជាជឿក៏មិនត្រូវយកមនុស្សទៅសម្លាប់ចោលដោយគ្មានការពិចារណា អ្នកដែលអត់កំហុស ។ អញ្ចឹងពេលនោះអ្នកបួសគឺអ្នកចេះដឹងមួយដែរ អ្នកចេះដឹងត្រូវមានការពិចារណាច្រើន ដឹងខុសដឹងត្រូវ ។ អញ្ចឹងពេលនោះបើសិនជាយើងនៅតស៊ូទៀតហាក់ដូចជាយើងធ្លាយ ចង់អប់រំប្រជាជនអីមួយអញ្ចឹងខ្លាចវាធ្វើទុក្ខយើង ។

ធានី ៖ ហេតុអីបានជាភូមិផ្សេងៗគេចាប់ផ្ដើមព្រះសង្ឃ ឬយកព្រះសង្ឃខ្លះទៅសម្លាប់ ហើយដល់ពេលភូមិលោកពូអត់មានគេយកទៅសម្លាប់?

គុណ ៖ ចំពោះភូមិនេះ បើព្រះសង្ឃដែលនៅវត្តផ្សេងៗ ព្រះសង្ឃអង្គខ្លះហ៊ានប្រឆាំង ហ៊ានតវ៉ាឧទាហរណ៍គេឲ្យចិញ្ចឹមមាន់ ចិញ្ចឹមទា ដល់ពេលយើងមានពីមុនវាឲ្យយើងយកដាក់រួមហើយអង្គខ្លះទៀតដល់ពេលលោកទេសនា ព្រះអង្គថាយើងដាក់រួមអស់ហើយឥឡូវ ឥឡូវបើយើងអាចចិញ្ចឹមបានសម្រាប់ជីវភាពមានតែចិញ្ចឹមឆ្កែ ដល់លោកថាអញ្ចឹង អាហ្នឹងគេថាលោកថាឲ្យលោក អញ្ចឹងចាប់លោកយកទៅសម្លាប់ បានន័យថាពេលលោកទេសអញ្ចឹងដាក់កម្ដៅឲ្យគេ ហើយលោកដឹង ហើយលោកអង្គទេសហ្នឹងយកទៅសម្លាប់នៅវត្តភ្នំ

ព្រៃវែងនេះ ហើយលោកវត្តព្រៃវែងហ្នឹងមួយទៀតចេះមន្តអាគមន៍អញ្ចឹងណា៎ ផ្ញើកថា ផ្ញើយ័ន្តឲ្យទាហាន គេតាមដានដឹងអញ្ចឹងណា៎

ធានី : អញ្ចឹងលោកអញ្ចឹងក៏គេយកដែរ?

គុណ : យកទៅសម្លាប់ចោលដែរ ។

ធានី : ឈ្មោះអីដែរ?

គុណ : ឈ្មោះ អ៊ុក លោកតា អ៊ុក ។ ហើយ អ៊ុក ហ្នឹងព្រះចៅអធិការវត្តព្រៃវែង លោកមាឌល្អិតតូច តែមិនដឹងជីតាលោកឈ្មោះអី អ៊ុក ទេខ្ញុំភ្លេចបាត់ហើយ ។

ធានី : ចុះម៉េចបានជាលោកគ្រូដឹងថាគាត់ហ្នឹងត្រូវបានគេយកទៅសម្លាប់?

គុណ : ពេលនោះខ្ញុំមិនទាន់សឹកទេ គេឲ្យលោកសឹកមុន អញ្ចឹងទៅសឹកនៅវត្តអន្តរន្ទ ពេលដែលសឹកហើយគេយកទៅចងតែម្ដង ។

ធានី : លោកគ្រូនៅជាមួយមែន?

គុណ : ពេលនោះខ្ញុំអត់បាននៅជាមួយទេ តែប្រជាជនប្រាប់ណា៎ ឃើញចាប់លោកហ្នឹងចង ចងដៃចងជើង ហើយទាញជើងដៃមកសឹកគ្នា បានសឹកអាសីដាក់លើរទេះសេះដូចជ្រូកអញ្ចឹង គេថាលោកពូកែ អញ្ចឹងគេយកទៅកន្លែងអប់រំគេភូមិតាម៉េងនេះ ភូមិតាម៉េងយើងខាងនេះ តាណោង ឪពុកខ្ញុំអីហ្នឹងគេយកទៅសម្លាប់ហ្នឹងដែរ នៅភូមិហ្នឹងដែរ ។

ធានី : កន្លែងហ្នឹងគេហៅអីគេដែរលោកគ្រូ ភូមិតាម៉េងហ្នឹង?

គុណ : តាម៉េង ហ្នឹងនៅវត្ត វត្តដែលខ្ញុំបង្រៀនរាល់ថ្ងៃហ្នឹងគឺគេយកទៅភូមិកន្លែងហ្នឹង ។

ធានី : វត្តហ្នឹងឈ្មោះអី?

គុណ : វត្តអាងស្វាយក្រោម ប៉ុន្តែក្រោយមកនៅតែវត្តអាងស្វាយទេ ហើយដល់ឆ្នាំ១៩៩៥បានបានលោកសុខ អាន លោកបានមកកសាងសាលាឲ្យបាន៣បន្ទប់ក្នុងមួយខ្នង ហើយក៏ឧទ្ទេសនាមសុខ អាន អាងស្វាយទៅ ។

ធានី : អញ្ចឹងលោកគ្រូ ពេលដែលគាត់សឹកហ្នឹងគេចាប់គាត់ ពេលគាត់សឹកហើយត្រូវបានគេចាប់ដាក់វត្តអាងស្វាយក្រោម?

គុណ : អត់ទេ តាអ៊ុក ហ្នឹងគេចាប់យកមកដាក់កន្លែងហ្នឹង ហើយគេទុកហ្នឹងទុករយៈពេលយូដែរ ប្រហែលជាកន្លះខែដែរ គេតាមដានណា៎ គេថាពួកលោកវត្តនេះវត្តនោះ ហើយបានអ្នកនៅខាងហ្នឹងបានប្រាប់មកដល់លោកវត្តកំពែងយើងថា ពេលដែល តាអ៊ុក នៅនោះថា ចំពោះលោកវត្តកំពែងនេះអត់មានពាក់ព័ន្ធជាមួយអាត្មាទេ កុំយកលោកវត្តកំពែងទៅសម្លាប់

ទៅធ្វើបាប កាលពេលហ្នឹងណា៎ ដល់ពេលពុប្រាប់អញ្ចឹងខ្ញុំថាមិនកើតទេ ដល់វត្តហ្នឹងស្លាប់ ហើយវត្តភ្នំឆ្នានោះមួយទៀតសម្លាប់អស់ទៀត ហើយវត្តខ្វែងហួសពីហ្នឹងទៅចូលដល់វត្តខ្វែងវត្តហ្នឹងខ្ទេចអស់ទៀតសល់តែនេនម្នាក់ទេ ។

ធានី : តែគេយកទៅសម្លាប់នៅកន្លែងវត្តអាងស្វាយក្រោមហ្នឹង?

គុណ : អត់ទេ លោកវត្តខ្វែងនោះយកទៅសម្លាប់មិនដឹងទីតាំងគេនៅកន្លែងណា ខ្ញុំអត់បានដឹងទេ កាលហ្នឹងវត្តខ្វែងហ្នឹងអស់អាលីង នៅតែនេនមួយទេ ឥឡូវហ្នឹងកំពុងតែត្រូវគ្នាជាមួយខ្ញុំ ហើយរាប់អានគ្នាដូចបងប្អូនអញ្ចឹង ព្រោះបានជីវិតរស់នៅ ហើយគ្នានៅនេនតូចណា៎ អញ្ចឹងគេយកតែលោកធំៗទៅសម្លាប់ចោល ចៅអធិការ ។

ធានី : អញ្ចឹងកាលហ្នឹងលោកគ្រូបានដឹងរឿងហ្នឹងពីណាមក ដែលថាគេប្រាប់ថាខាងលោកតាអ៊ុក ហ្នឹងគាត់ឆ្លើយប្រាប់ថាមិន?

គុណ : ប្រជាជនគាត់ប្រាប់ ព្រោះនៅនោះប្រជាជនភូមិតាម៉េងមកចូលរួមនៅវត្តកំពែងនេះដែរ យកចង្ហាន់យកអីមកអញ្ចឹង ហើយគាត់ក្នុងការអាណិតលោក មានការអាណិតលោកអញ្ចឹងទៅ ហើយមកហ្នឹងក៏មិនមែនមកចំហរដែរ លោកនិយាយដោយស្ងាត់ស្ងៀម ថាឲ្យព្រះអង្គប្រុងប្រយ័ត្នពាក្យពេជន៍ ពាក្យសម្តី ការនិយាយពីរឿងអីមួយផ្សេងៗមិនបាច់និយាយអីទេ ព្រះអង្គដឹងតែរៀនធម៌ដឹងតែធ្វើការទៅ យប់រៀនធម៌ ថ្ងៃឡើងដាំដំឡូងទៅហើយនឹងធ្វើការទៅ សម្របសម្រួលខ្លួន ហើយខ្ញុំពុអញ្ចឹងក៏ភ័យខ្លួន ។

ធានី : ក៏ចាប់ផ្តើមពិភាក្សាហើយសឹកហ្មង?

គុណ : បាទ! បបួលចៅអធិការហ្នឹង អញ្ចឹងពេលនោះឯងលោកក៏ឯកភាព ប៉ុន្តែភ័យហ្នឹងភ័យដោយជាក់ស្តែង ពេលដែលគេយកលោកទៅសម្លាប់ចោល គេឲ្យឈ្លបមកស៊ើបក្រោមវត្តរាល់យប់ហ្នឹង យប់ណាក៏មកដែរ ។

ធានី : ខាងណាអ្នកចេញបញ្ជាឲ្យយកគាត់ទៅសម្លាប់?

គុណ : ចំពោះអ្នកដែលបញ្ជាឲ្យយក តាអ៊ុក ហ្នឹងទៅសម្លាប់គឺខ្ញុំអត់ដឹងដែរ តែនៅក្នុងនោះមានមេឃុំមានតែគេហៅ តាញ៉ែតៗ ហ្នឹងដែលខ្លាំង សម្លាប់មនុស្សសម្លាប់មាំុណាស់ក្នុងឃុំនេះអស់ច្រើនណាស់ ។

ធានី : លោកគ្រូធ្លាប់ឃើញទេ?

គុណ : តាញ៉ែត ហ្នឹង?

ធានី : ចា៎!

គុណ :	តាញ៉ែត ហ្នឹងធ្លាប់ឃើញ មាឌសខ្ពស់ តាញ៉ែត ហ្នឹងដល់ហើយទៅត្រូវ វាខូចជាមួយស្រីច្រើនណាស់រហូតមានកូនចៅក្នុងភូមិកំពែង នៅពេទ្យខាងក្រោយផ្ទះនេះ ដោយសារឪពុកក្មេកខ្ញុំទៅទាន់ជាមួយពេទ្យស្រីហ្នឹង អញ្ចឹងមិនដឹងធ្វើម៉េចមានតែចាប់គាត់យកទៅសម្លាប់ចោលដើម្បីបំបិទមាត់ អញ្ចឹងក្រោយមកដល់ពេលបែកការណ៍ថាវាខូចស្រីច្រើន អញ្ចឹងអភិបាលស្រុករបស់គេជំនាន់នោះឈ្មោះ តាសុំ ជាមួយ យាយបូ គេឲ្យចាប់មេឃុំហ្នឹងហ្នង ព្រោះវាធ្លាយច្រើនបានសំណុំរឿងបែបបទហ្នឹងច្រើន ហើយដឹងថា តាញ៉ែត ហ្នឹងវាខូច អញ្ចឹងពេលនោះ តាញ៉ែត រៀបចំផែនការរត់ទៅវៀតណាម នាំតែប្រពន្ធចុងក្រោយទៅវៀតណាម ។

ធានី :	ហើយបានរួចទេ?

គុណ :	អត់រួចទេ ទៅដល់គេស្ទាក់ជាប់ រួមជាមួយកងទ័ពខ្មែរក្រហម ហើយចាប់បានទៅ ដល់ពេលចាប់បានបញ្ជូនមកចូលកន្លែងខ្ញុំដុំដែកនៅសុបិន្តនេះ ដែលខ្ញុំថាសឹកហើយនៅដុំដែកហ្នឹងគេចងអញ្ចឹង ។

ធានី :	តែគាត់ម្នាក់ឯងទេ?

គុណ :	បាទ! តែមួយហ្នឹង តែតាញ៉ែត ហ្នឹង ។

ធានី :	ហើយផ្សេងៗអត់ឃើញទេ?

គុណ :	អត់ឃើញទេ ។

ធានី :	ហើយគេចងហើយធ្វើម៉េចទៀតទៅ?

គុណ :	ក្រោយមកត្រូវបញ្ជូនជាមួយពួកខ្មែរយើង ខ្មែរកម្ពុជាក្រោម គេបញ្ជូនឡើងទាំងឡានៗគេបញ្ជូនឡើងទៅលើតែមិនដឹងទៅណាទេ ។

ធានី :	ឡើងលើហ្នឹងទៅទិសខាងណា?

គុណ :	ទៅដើងទៅ ទៅអញ្ចឹងទៅកំពត ទៅត្រពាំងអណ្តើក ប៉ុន្តែខ្លះគេថាបែបបំបែកទៅក្រោមវិញទៅសម្លាប់ទាំងអស់ ។

ធានី :	បំបែកទៅក្រោមហ្នឹងទៅកន្លែងណាវិញលោកគ្រូ?

គុណ :	ទៅក្រោមហ្នឹងបើតាមមើលបែបចុះយើងសៀរមកអញ្ចេះកាត់មកកំពតអញ្ចេះ ។

ធានី :	អាចនិយាយដូចថាទៅកន្លែងណាមួយលោកគ្រូ?

គុណ :	មិនអាចដឹង ខ្ញុំមិនដឹងដែរ ។

ធានី :	ប្រហែលទៅកំពតទៅអីដែរ?

គុណ :   ប្រហែលកំពតទៅអញ្ចេះទៅ ឡើងទៅត្រពាំងអណ្ដើក ជីវិរមៀលទៅឡើងទៅកំពតហើយ ព្រោះតំបន់ភ្នំ ។

ធានី :   ប៉ុន្តែដឹងថាកន្លែងហ្នឹងជាកន្លែងអីទេ បានជាគេបញ្ជូនទៅហ្នឹង?

គុណ :   អត់ដឹងកន្លែងអីទេ គេថាជម្លៀសយកទៅលើៗ ព្រោះកាលនេះប្រជាជនយើងនៅនេះហ្នឹង អ្នកដែលជាប់ពាក់ព័ន្ធគ្រួសារធ្វើទាហានឲ្យទៅមន្ទីរ២០៨ហើយ ។

ធានី :   មន្ទីរ២០៨?

គុណ :   បាទ! ម្ដាយខ្ញុំបង្កើតបានទៅនោះដែរ ។

ធានី :   កន្លែងអីគេមន្ទីរ២០៨ហ្នឹង?

គុណ :   គេហៅកន្លែងអប់រំគេ ។

ធានី :   អប់រំយ៉ាងម៉េចទៅលោកគ្រូ?

គុណ :   អប់រំហ្នឹងគឺ គេយកទៅគេដាក់កន្លែងវាលបែសហ្នឹង គាត់ថាគ្មានអីទេ មានតែគល់ព្រិច មាន អីឲ្យយើងទៅបង្ករបង្កើនសាច់រានដីដាំដំណាំបង្ករបង្កើនកន្លែងហ្នឹង ។

ធានី :   យើងគ្រាន់តែដាំដំណាំអត់មានធ្វើអីផ្សេងទៀតទេ?

គុណ :   អត់មានធ្វើអីទេ ខ្ញុំផ្ទះត្រង់នេះបន្តិច ផ្ទះបញ្ចាំងពីប្រវត្តខ្លួនឯងហ្នឹង ក្រោយពេលដែលខ្ញុំនៅបួសលោកហ្នឹងគឺម្ដាយខ្ញុំហ្នឹង បងស្រីខ្ញុំហ្នឹងទាហានគេដណ្ដឹង ដល់ពេលទាហានគេដណ្ដឹងមិនដឹងធ្វើម៉េច បើមិនឲ្យគេចាប់ អញ្ចឹងគាត់ក៏សម្រេចឲ្យ អញ្ចឹងពេលសម្រេចឲ្យគាត់ក៏បានទៅប្រាប់បងប្អូនយើងនៅខាងខេត្តកំពត ព្រោះទាហានវានៅម្ដុំគិរីវង់មកវត្តភ្នំយើងនេះណា៎ មកដល់វត្តភ្នំជីតាពិច អាភ្នំជីតាពិចព្រះលោកយាយរាល់ថ្ងៃហ្នឹង អញ្ចឹងទាហាននៅលើហ្នឹង អញ្ចឹងពេលនោះគាត់បានសម្រេចថាឲ្យអញ្ចឹងហើយ គាត់ទៅប្រាប់បងប្អូនស្មានតែមិនអីទេ ពេលទៅប្រាប់នៅខេត្តកំពតនេះឆ្លងពីនេះទៅ អញ្ចឹងពេលហ្នឹងខ្មែរក្រហមវានៅហ្នឹង ថ្ងៃថយទៅហ្នឹងយប់ឡើងវាចូលមកដល់តំបន់យើងនេះ អញ្ចឹងពេលទៅដល់គេចាប់គាត់ គេថាយើងសេអ៊ីអា ម្ដាយខ្ញុំហ្នឹង ខ្ញុំហៅម្ដាយថាញោម គេថាគាត់សេអ៊ីអាយកការឲ្យទាហាន អញ្ចឹងគេចាប់គាត់ ខ្ញុំអត់ដឹងថាគេចាប់ទេ ប៉ុន្តែដល់បាត់មួយយប់សួរញោមប្រុសគាត់ថា ញោមលោកទៅប្រាប់ការបងប្អូនជីដូនមួយអីហ្នឹង អញ្ចឹងខ្ញុំព្រលឹមឡើងខ្ញុំទៅទៅដល់ជួបអ្នកដែលស្គាល់គ្នា អ្នកនៅកំពតហ្នឹងថាញោមលោកគេបញ្ជូនទៅលើហើយ អញ្ចឹងតាមម្ដាយទៅដល់ក្បែរជើងភ្នំវត្តរ៉ូបនេះ ដល់ហើយនឹងឃើញមិនដឹងទៅរកនៅណាទេ

មិនដឹងមុខមិនដឹងមាត់ទៅណាទៅណើអញ្ចឹង បានគេឲ្យឈ្លបគេថា ឥឡូវបើគេគុណចង់តាម ក៏តាមចុះ កាលហ្នឹងសុំហៅលោកនេនមួយអង្គទៀតទៅជាមួយខ្ញុំ ដល់ពេលលោកនេននោះខ្លាច ករុណាខ្លាចលោកបងទៅក៏ទៅ ករុណាមិនទៅទេ អញ្ចឹងក៏សម្រេចចិត្តមកវិញ ពេលសម្រេចចិត្តមកវិញបានមួយអាទិត្យគេសរសេរសំបុត្រដាក់នៅខាងក្រោយផ្ទះញោមប្រុសហ្នឹងថា ធ្វើបុណ្យឲ្យគាត់ទៅគេសម្លាប់គាត់ហើយ អញ្ចឹងពេលនោះមិនដឹងធ្វើម៉េចទេ បងខ្ញុំយំផង ឪពុកយំប្រាប់ខ្ញុំលោកអញ្ចឹង ថាធ្វើចង្ហាន់ទៅគ្មានអីទេ លោកនៅហ្នឹងមានចង្ហាន់តិចតួចណាស់ ធ្វើបុណ្យឲ្យគាត់ ខទ្ទិសឲ្យគាត់ អញ្ចឹងពេលហ្នឹងគាត់ទៅដល់មន្ទីរ២០៨ហ្នឹងហើយ កាលហ្នឹងនៅក្នុងស្រុកត្រាំកក់ មន្ទីរ២០៨ ប៉ុន្តែឥឡូវគេកាត់ចូលក្នុងស្រុកជុំគិរី អញ្ចឹងពេលនោះខ្ញុំនៅឆ្នាំ៧៨ហ្នឹងគេឲ្យឡើងទៅលើហ្នឹងបានទៅលើហើយ អញ្ចឹងពេលចាប់ទៅហ្នឹងបានរយៈពេល៣ខែ អប់រំបាន៣ខែក៏ទាហានបែកលើភ្នំជីតាពិច អញ្ចឹងទាហានដែលបែកមកគេអត់ទាន់សម្លាប់ទេ អញ្ចឹងគេឲ្យទៅរៀននៅលើ លើហ្នឹងគឺនៅ២០៨ហ្នឹងឯងទៅជួបកូនប្រសារហើយម្តាយក្មេកទៅជួបគ្នានៅហ្នឹង អញ្ចឹងម្តាយខ្ញុំរយៈពេល៣ខែត្រូវគេឲ្យមក ដល់ពេលបងត្រូវធ្វើទាហានគេឲ្យរៀនហ្នឹង៣ខែទៀតបានមក អញ្ចឹងគាត់ត្រូវឌុប៣ខែទៀតឡើង៦ខែ អញ្ចឹងពេលនោះគាត់ចូល៨០ ចូល៨០ហើយបានមកជួបកូនចៅរហូតចុះមកដល់ពេលឥឡូវហ្នឹងមកគាត់ទើបតែស្លាប់ ។

ធានី : គាត់អាយុវែងណា៎?

គុណ : បាទ! គាត់អាយុ៩៣ ម្តាយខ្ញុំ ។

ធានី : អញ្ចឹងកូនប្រសារគាត់ឈ្មោះអីគេ?

គុណ : កូនប្រសារគាត់ឈ្មោះ មុំ ដាន់ ហ្នឹងបងថ្លៃខ្ញុំ ។

ធានី : ចុះលោកគ្រូថាវត្តអីគេ គេច្រើនយកព្រះសង្ឃទៅសម្លាប់ មានវត្តមួយដែលលោកនេនគាត់នៅរស់ដែរ គាត់ឈ្មោះអីដែរ?

គុណ : ឈ្មោះ ដុន ។

ធានី : អី ដុន លោកគ្រូ?

គុណ : ឪពុកគាត់ឈ្មោះ ហ៊ីម អញ្ចឹងខ្ញុំហៅ ហ៊ីម ដុន ។

ធានី : គាត់នៅក្នុងភូមិឃុំណាលោកគ្រូ?

គុណ : គាត់នៅភូមិត្រពាំងព្រីង ។

ធានី : ឃុំ?

គុណ ៖ ឃុំគោកព្រិច ស្រុកគិរីវង់ដែរ ។

ធានី ៖ អញ្ចឹងលោកគ្រូ ម្ដាយលោកគ្រូដែលថាធ្លាប់នៅ២០៨ហ្នឹង ពេលហ្នឹងលោកគ្រូទៅធ្វើជាង?

គុណ ៖ បាទ! ពេលហ្នឹងខ្ញុំនៅលោកទេ ដល់ហើយនៅក្នុងឆ្នាំ៧៨ហ្នឹងបានគេឲ្យមកវិញ ហ្នឹងចាប់សឹកហើយ ។

ធានី ៖ អញ្ចឹងដល់ពេលដែលលោកគ្រូទៅ ម៉េញលោកគ្រូថាមុនហ្នឹងលោកគ្រូបានទៅធ្វើជាងហ្នឹងហើយ ក្រោយពីចិញ្ចឹមជ្រូកគេឲ្យធ្វើជាង?

គុណ ៖ បាទ! គេឲ្យធ្វើជាង ។

ធានី ៖ ដល់ពេលលោកគ្រូនៅចិញ្ចឹមជ្រូកហ្នឹងខាងណាគេឲ្យលោកគ្រូ យាយបូ គាត់អ្នកប្រាប់?

គុណ ៖ គេមានចាត់តាំងប្រធានគេមួយ គឺយាយមួយឈ្មោះ យាយសុទ្ធៗ ជាអ្នកមើលការខុសត្រូវ ។

ធានី ៖ អ៎! យាយសុទ្ធ ហ្នឹងគាត់អ្នកមើលការខុសត្រូវ?

គុណ ៖ បាទ! គាត់អ្នកមើលការខុសត្រូវ ។

ធានី ៖ ចិញ្ចឹមជ្រូកហ្នឹង?

គុណ ៖ បាទ!

ធានី ៖ ក្រោយមកទៀតយ៉ាងម៉េចទៀត លោកគ្រូថាគេចិញ្ចឹមជ្រូកហ្នឹងនៅឆ្នាំប៉ុន្មានដែរ?

គុណ ៖ នៅឆ្នាំ១៩៧៥ ។

ធានី ៖ ចុះពេលលោកគ្រូធ្វើជាង?

គុណ ៖ ធ្វើជាងហ្នឹងក្នុងឆ្នាំ៧៥-៧៦-៧៧ ។

ធានី ៖ ហើយខាងណាអ្នកបញ្ជូនឲ្យលោកគ្រូទៅធ្វើជាង?

គុណ ៖ ចៅហ្វាយស្រុកគេ ។

ធានី ៖ ចៅហ្វាយស្រុក?

គុណ ៖ បាទ! យាយបូ ហ្នឹងហ្នង ។

ធានី ៖ លោកគ្រូស្គាល់គាត់ច្បាស់ទេ?

គុណ ៖ បាទ! យាយបូ ហ្នឹងខ្ញុំស្គាល់ច្បាស់ ។

ធានី ៖ រូបរាងគាត់យ៉ាងម៉េចដែរ?

គុណ ៖ រាងធាត់ក្រអាញ មិនក្រអាញទេ បានន័យខ្ពស់មិនខ្ពស់ទាបមិនទាប ។

ធានី ៖ ហើយសប្បុរគាត់យ៉ាងម៉េចដែរ?

គុណា ៖ សប្បុរសណ្ដែកបាយ ។

ធានី ៖ គាត់កាចទេ?

គុណា ៖ ទេ បើតាមខ្ញុំធ្លាប់នេះទៅ ព្រោះខ្ញុំធ្លាប់ចិញ្ចឹមជ្រូកហ្នឹង ដល់ពេលខ្ញុំខ្យល់ចាប់អីគាត់ ខ្ញុំកោសអត់បាន ដល់កោសអត់បានពួកយាយៗ ពួកពូៗដែលជាយុទ្ធជននៅជាមួយគ្នាហ្នឹង ចាប់ខ្ញុំ ចាប់ខ្ញុំដល់ហើយខ្ញុំថាអត់ឲ្យកោសទេ ស្រាប់ដល់គាត់ហៅខ្ញុំថា មិត្តគុណា មកដេក កន្លែងនេះ ខ្ញុំខ្លាចគេដល់ហើយទៅដេក ដល់ពេលដេកគាត់ចាប់កោស ដល់គាត់កោសអត់ហ៊ានរ៉ើដែរ ។

ធានី ៖ អ៊ំ! យាយបូ ហ្នឹងកោសឲ្យលោកគ្រូហ្នង?

គុណា ៖ បាទ! ព្រោះអ្នកដទៃកោសខ្ញុំមិនឲ្យកោស ខ្ញុំឈឺ ដល់ពេលគាត់ហៅឲ្យទៅដេកខ្ទបឲ្យគាត់កោសខ្លាចគាត់ ខ្ញុំមិនដែលកោសទេ ។

ធានី ៖ ចុះម៉េចបានជាគាត់កោសខ្យល់ឲ្យលោកគ្រូ?

គុណា ៖ ព្រោះពេលហ្នឹងគាត់ទៅមើលជ្រូក ហើយចៃដន្យយាយហ្នឹងថា មិត្តគុណា ខ្យល់មាំណាស់ ហើយអត់ឲ្យគេកោសគេចាប់អីទេ ចុះឥឡូវទៅណាហើយ ហើយថានៅនោះ ដល់ហើយបានគាត់ថា មិត្តគុណា មកនេះ ដល់ពេលខ្ញុំមកដល់គាត់ថាខ្ទបមើល៉ យាយយកប្រេងមើល៉ គាត់គ្រាន់តែកោសបានមួយចំហៀងខ្នងគាត់ឲ្យផ្កា ដល់ពេលផ្កាគាត់ហៅយុទ្ធជនប្រុសៗ ដូចគ្នា មើលឯងមកកោសមើល៉ មិត្តគុណា រ៉ើអត់ ហើយខ្ញុំមានហ៊ានរ៉ើណា៎ អញ្ចឹង យាយបូ គឺខ្ញុំស្គាល់ច្បាស់ណាស់ ។

ធានី ៖ អញ្ចឹងយាយបូ ហ្នឹងគាត់ស្គាល់លោកគ្រូដែរ?

គុណា ៖ បាទ! ស្គាល់ ព្រោះនៅចិញ្ចឹមហ្នឹងគាត់ចេញចូលញឹកញាប់ ។

ធានី ៖ អញ្ចឹងកន្លែងចិញ្ចឹមជ្រូកហើយកន្លែងគាត់នៅជិតគ្នាដែរ?

គុណា ៖ អត់ទេ មន្ទីរគាត់នៅដោយឡែក ។

ធានី ៖ មន្ទីរហ្នឹងនៅកន្លែងផ្សេងទៀត?

គុណា ៖ បាទ! នៅដោយឡែកផ្សេងទៀត ។

ធានី ៖ ប៉ុន្តែគាត់អាសាររមកមើល?

គុណា ៖ គាត់អាសាររមកមើលកន្លែងដាក់ ចិញ្ចឹមជាកសិដ្ឋានកាលហ្នឹង វាយកវត្ថុដាក់ធ្វើជាទ្រុងជ្រូកហើយ ។

ធានី ៖ អញ្ចឹងលោកគ្រូ អ្នកណាគេបញ្ជូនលោកគ្រូឲ្យទៅធ្វើនៅ....?

គុណ ៖ គឺយាយហ្នឹងដែរ ហើយដល់ខ្ញុំនៅកន្លែងចិញ្ចឹមជ្រូកហ្នឹងធ្វើរបងធ្វើអញ្ចឹង ធ្វើគ្រែដេកធ្វើអីអញ្ចឹងទៅ ខ្ញុំចេះច្នៃធ្វើធុងសម្រាប់ត្រងទឹកភ្លៀង យកស័ង្កសីយើងកាត់ធ្វើធុង ព្រោះកាលខ្ញុំរៀនជាងដែកខ្ញុំរៀននៅអនុវិទ្យាល័យខ្ញុំរៀនខាងកសិកម្ម ខ្ញុំចេះធ្វើធុង ធ្វើប៉ែនយើងវេញនំបញ្ចុក ហើយអញ្ចឹងឥឡូវហ្នឹងខ្ញុំចងចាំ អញ្ចឹងមានស័ង្កសីមានកន្ត្រៃខ្ញុំអាចកាត់ធ្វើធុងបាន ។

ធានី ៖ អញ្ចឹងក្រោយមកទៀតលោកគ្រូទៅរៀនហ្នឹង រៀននៅកន្លែងណា នៅខេត្តតាកែវ?

គុណ ៖ នៅខេត្តតាកែវហ្នឹងសព្វថ្ងៃនៅកន្លែងសាលា ជា ស៊ីម ហ្នឹងហ្មង វិទ្យាល័យជា ស៊ីម ហ្នឹង

ធានី ៖ ហើយទៅរៀនប៉ុន្មាននាក់ដែរលោកគ្រូ?

គុណ ៖ ទៅតែ២នាក់ តាមួយគាត់ខាងឈើ ទៅរៀនខាងកីតម្បាញ ។

ធានី ៖ ឈ្មោះអីដែរ?

គុណ ៖ ឈ្មោះ ថន ។

ធានី ៖ សព្វថ្ងៃគាត់នៅរស់ទេ?

គុណ ៖ សព្វថ្ងៃគាត់នៅរស់ ។

ធានី ៖ គាត់នៅណាដែរ?

គុណ ៖ នៅភូមិពន្លៃ ហើយតាមួយទៀតគាត់ទៅមុនខ្ញុំ ខ្ញុំអត់ដឹងទេ ដល់ពេលខ្ញុំទៅបានដឹងថាគេបញ្ជូនគាត់ទៅរៀនដែរ តាហ្នឹងគាត់ខាងជាងម៉ាស៊ីន ។

ធានី ៖ ឈ្មោះអីគេ?

គុណ ៖ ឈ្មោះ តាជា ។

ធានី ៖ គាត់នៅភូមិអីដែរ?

គុណ ៖ នៅភូមិតាពៅ ឃុំកំពែងដែរ អញ្ចឹងទៅដល់នោះឃើញគាត់នៅហ្នឹង គាត់ខាងធ្វើម៉ាស៊ីនគ្រឿងម៉ាស៊ីនគ្រឿងអីហ្នឹង អញ្ចឹងក្រោយមកដល់ហើយអញ្ចឹងទៅបាននៅគ្រឿងម៉ាស៊ីនជាងឆ្នាំងជាងដែកហ្នឹងគេដាក់នៅក្បែរគ្នាមួយដុំនៅគិរីវង់ហ្នឹង

ធានី ៖ ពេលដែលលោកគ្រូទៅរៀនហ្នឹង ពីណាគេអ្នកបង្រៀនលោកគ្រូ?

គុណ ៖ មេជាងគេនៅក្នុងកន្លែងសិប្បកម្មខេត្តហ្នឹងហ្មង កន្លែងខេត្តគេហ្នឹងហ្មង ។

ធានី ៖ មេជាងគេឈ្មោះអីគេដែរលោកគ្រូ?

គុណ : ខ្ញុំអត់បានស្គាល់ឈ្មោះគេទេ គេអត់បានប្រាប់ យើងទៅវាឲ្យយើងអនុវត្តផ្ទាល់ហ្មង យើងចេះពីនេះទៅយ៉ាងម៉េចយើងធ្វើទៅគេប្រាប់យើង គេថារបៀបស្លដែក ប៉ុន្តែស្លដែកខ្ញុំនៅនេះស្លប្រើខសចំបក់ កាត់ដើមចំបក់ធំៗអញ្ចឹងហើយយកមកពុះ ដល់ពុះវាហើយយកមកធ្វើឆ្នាំងដាក់កម្តៅក្រឡគេប៉ុណ្ណឹង អញ្ចឹងហើយមកយើងដាក់ឆ្នាំងស្លដែកកណ្តាលទៅ ហើយដាក់ខសសងខាង ដល់ពេលនោះដែកដេរ៉ាវាត្រូវភ្លើងរលាយហើយ ពេលរលាយហើយបានដងទឹកដែកយកទៅចាក់ពុម្ពឆ្នាំង ។

ធានី : គេបង្រៀនយើង?

គុណ : មុនដំបូងខ្ញុំទៅមើលគេ ដល់មើលគេអញ្ចឹងឃើញខ្ញុំវាងឆាប់ចាប់បានអញ្ចឹង គេឲ្យខ្ញុំទៅរៀនថែមដើម្បីឲ្យចាក់ឆ្នាំងខ្វះ កាលហ្នឹងយើងចាក់ឆ្នាំងតូចៗ អាឆ្នាំងក្នុងមួយគ្រួសារ៥-៦នាក់អាចដាំបាយបាន ដល់អញ្ចឹងគាត់ថាមិត្តឯងអាចច្នៃអាចចាក់ឆ្នាំងធំៗបាន ខ្ញុំថាអាចបានបើថាបានមិត្តឯងទៅរៀនថែមទៀត ដល់ហើយឲ្យខ្ញុំទៅរៀនទៀត ។

ធានី : អ្នកណាអ្នកសួរ?

គុណ : យាយបូ ហ្នឹង ។

ធានី : អញ្ចឹងដល់ពេលលោកគ្រូទៅរៀនហ្នឹងបានរយៈពេលប៉ុន្មានដែរ?

គុណ : ខ្ញុំបាន៣ខែ ពេលដែលបាន៣ខែហ្នឹង ខ្ញុំទៅរៀនពេលនោះគឺការហូបចុកអីក៏មិនបបូរដែរសម័យនោះ ស្មានតែថាគ្រាន់បើហូបគ្រប់គ្រាន់បានខ្ញុំទៅ អញ្ចឹងចេះតែអត់ធ្មត់ ហើយមិនចង់រៀនទៀតដល់ពេលមើលឃើញវាលំបាកពេលរៀនទៅ ចុះភ្លើងវាក្តៅ ថាចង់ថយវិញដល់ហើយថយវាមិនកើត ដាច់ខាតត្រូវតែយកទៅនោះ នៅអត់បានទេមកពីរៀន ។

ធានី : អញ្ចឹងដល់ពេលលោកគ្រូទៅហ្នឹងនៅឆ្នាំប៉ុន្មានដែរ?

គុណ : ខ្ញុំទៅរៀននៅឆ្នាំ១៩៧៧ ដើម៧៧ ។

ធានី : ដើម៧៧?

គុណ : បាទ! ពេលដែលមកធ្វើហ្នឹង ធ្វើបានរយៈពេលជាងមួយឆ្នាំ កាលមុនមកខ្ញុំចេះតែនៅជាមួយគេឯង ក្រោយមកដល់ពេលយើង៧៧ហ្នឹង មកចុង៧៧វារំដើបរំជួលហើយវៀតណាមបុកក្បែហ្នឹង ប៉ុន្តែមិនទាន់បានធ្វើឲ្យជាងដែកហ្នឹងវាបារម្ភអីទេ វាមានទ័ពនៅការពារហ្នឹងហើយ អញ្ចឹងដល់ក្រោយមកទៀត ចូលដល់ឆ្នាំចុង៧៧ដើម៧៨ អញ្ចឹងវៀតណាមធ្វើការបុកហើយ មានការផ្ទោង មានការបាញ់ កាលហ្នឹងខ្មែរក្រហមវាបានបុកទៅប្រទេសវៀតណាម នៅម្តុំគេហៅសំបុកមាន់នៅទឹកដីវៀតណាមហ្នឹងណា៎ អញ្ចឹងបុកចូលទៅ

អញ្ចឹងពេលនោះគឺបុកចូលទៅ ក្រោយមកវៀតណាមបុកមកវិញមក បុកដេញមកហួសមក ហើយក៏បាក់ទ័ពប៉ុល ពត អញ្ចឹងក្រោយមកវៀតណាមដកទៅវិញ យើងធ្វើការដេញទៅវិញ ខ្មែរក្រហមគេដេញទៅវិញ វៀតណាមក៏ទៅដល់ប្រទេសគេវិញទៅ ។

ធានី : អញ្ចឹងពេលហ្នឹងលោកគ្រូចូលធ្វើទ័ព?

គុណា : ពេលនោះដកហ្នងជាងដែកហ្នឹង ចៅហ្វាយស្រុកគេឈ្មោះគេ តាសៀង១ ពួកគេហៅ សៀង តែមិនដឹងអីសៀង ទេ ខ្ញុំមិនស្គាល់ជីតា សម័យនោះគេហៅតា១ ឲ្យតែអ្នកធំគេហៅតាហើយ ទោះបីក្មេងក៏ដោយ ហើយមីងអីគេហៅយាយហើយ ហើយយាយបូ ហ្នឹងចំណាស់ក៏មិនប៉ុន្មានដែរ កាលហ្នឹងប្រហែលជាខ្ទង់៤០មិនដឹង ប៉ុន្តែគេចេះតែហៅយាយទៅ ៤០ ជាងអីហ្នឹង ។

ធានី : តាសៀង ហើយនឹងយាយបូ ហ្នឹងមួយណាជាមេធំ?

គុណា : អញ្ចេះ យាយបូ ហ្នឹងគឺគាត់មុនគេ តាំងពីទាហាននៅក៏មានឈ្មោះ យាយបូ ហ្នឹងដែរ អញ្ចឹងពេលទាហានចេញទៅក៏នៅ យាយបូ ហ្នឹងដែរ អញ្ចឹងតាសៀង ហ្នឹងគឺគាត់ចុងក្រោយហើយ ចៅហ្វាយស្រុកចុងក្រោយនៅឆ្នាំ៧៧-៧៨ហើយទេ ហើយតាគុំ តាទិត អីហ្នឹងទៅបាត់អស់ហើយ គេផ្លាស់ចេញបាត់អស់ហើយ ។

ធានី : អញ្ចឹងតាគុំ ហើយនឹង តាទិត ហ្នឹងសុទ្ធតែជាមួយគ្នាដែរ?

គុណា : តាគុំ, តាទិត, ហើយនឹងយាយបូ គឺ៣នាក់ហ្នឹងប្រមូលគ្នា ។

ធានី : ដូចថាគាត់ទៅណាវិញទេ?

គុណា : បាទ! តាគុំ ហ្នឹងដល់ហើយទៅគាត់ស្លាប់ ហើយយាយបូ ហ្នឹងនៅទៅបែករត់ទៅលើទៅជួប ប្រជាជនគេជួបដែរ ប្រជាជនយើងរត់ទៅឆ្ងាយនៅទល់ដែនថៃហ្នឹងបានជួបគាត់ដែរ ប៉ុន្តែខ្ញុំអត់បានជួបទេ ខ្ញុំអត់ទៅឆ្ងាយទេ ។

ធានី : កាលហ្នឹងហេតុអីបានជា យាយបូ គាត់លែងរស់នៅស្រុកហ្នឹង ហើយឲ្យ តាសៀង មកវិញ?

គុណា : ខ្ញុំអត់ដឹងដែរការផ្លាស់ប្តូររបស់គេ ថ្នាក់គេហ្នឹងមិនដឹងជាគេផ្លាស់ប្តូរយ៉ាងម៉េចខ្ញុំអត់ដឹងដែរ ។

ធានី : ចុះម៉េចគាត់ផ្លាស់ប្តូរទៅណាវិញ លោកគ្រូដឹងទេ?

គុណា : មិនដឹងទេ មិនដឹងជាគេឡើងទៅខេត្តទៀត ឬក៏ទៅខាងណាទៀតខ្ញុំអត់ដឹង យើងអត់ដឹងផែនការគេយើងមិនអាចដឹងដែរ ។

ធានី : ចុះក្រៅពី យាយបូ, តាទិត, តាគុំ អីហ្នឹង មានអ្នកផ្សេងដែលត្រូវផ្លាស់ប្តូរដូចគាត់ទេ?

គុណ ៖ ឃើញមកក្រោយហ្នឹងមានតែ តាសៀង ហ្នឹងហ្នង ហើយស្រីគឺអត់មានទេ ស្រីអត់មានឃើញទេ ។

ធានី ៖ គាត់កាចទេ តាសៀង ហ្នឹង?

គុណ ៖ តាសៀង ចៅហ្វាយស្រុកក្រោយមកមិនដែលឮសម្លាប់ទេ ចៅហ្វាយស្រុកក្រោយហ្នឹងខ្ញុំមិនបានឃើញទេ តែក្រែងលោគេសម្លាប់សម្ងាត់អីយ៉ាងម៉េចខ្ញុំអត់ដឹងទេ ។

ធានី ៖ ប៉ុន្តែបើឮគឺឮតែ យាយបូ ទេ?

គុណ ៖ បាទ! ឮតែយាយបូ តែយាយបូហ្នឹងខ្ញុំមិនដែលនៅជាមួយមិនដែលបានឃើញគាត់សម្លាប់ផ្ទាល់ដៃ តែក្រែងលោគាត់បញ្ជា គាត់បញ្ជាក្រោមឱវាទរបស់គាត់ គាត់មានសេនាជន មានឈ្លបមានអីរបស់គាត់ ។

ធានី ៖ តែលោកគ្រូធ្លាប់ឃើញទេ?

គុណ ៖ ការសម្លាប់ខ្ញុំមិនដែលបានឃើញទេ តែបើចងខ្ញុំធ្លាប់ឃើញ ចងបណ្តើរ តែបើគេសម្លាប់ខ្ញុំមិនដែលបានឃើញទេ ។

ធានី ៖ ចងបណ្តើរពីណាទៅណាដែរ?

គុណ ៖ តាមផ្លូវហ្នឹង បណ្តើរតាមផ្លូវភូមិហ្នឹងទៅ ។

ធានី ៖ ទៅណាវិញ?

គុណ ៖ គេយកទៅអញ្ជឹងទៅ មានអ្នកណាហ៊ានតាម គ្រាន់នឹកឃើញហ្នឹងរួញខ្លួននៅក្នុងផ្ទះ មិនហ៊ានទេ ។

ធានី ៖ កាលហ្នឹងនៅ យាយបូ ហ្នឹងគាត់គ្រប់គ្រង?

គុណ ៖ បាទ! នៅយាយបូ ហើយនឹងតាញ៉ែតហ្នឹង ។

ធានី ៖ តាញ៉ែត?

គុណ ៖ តាញ៉ែត មេឃុំហ្នឹង ចាប់ឪពុកក្មេកខ្ញុំហ្នឹង ។

ធានី ៖ ពេលដែលលោកគ្រូឃើញ លោកគ្រូថាអត់ដែលឃើញ ចុះម៉េចបានជាលោកគ្រូថាអ្នកណាខ្លះដែលគេយកទៅសម្លាប់នៅវត្តអាងស្វាយហ្នឹង?

គុណ ៖ វត្តអាងស្វាយបានជាខ្ញុំដឹងគឺ កាលដែលទៅចាប់គាត់ហ្នឹងគឺខ្ញុំនៅជាងដែកទេ ខ្ញុំនៅជាងដែកតែខ្ញុំដឹង ចាប់ឪពុកក្មេកខ្ញុំនេះ អញ្ជឹងចាប់ឪពុកក្មេកខ្ញុំហើយនឹងអ៊ីនៅនេះហ្នឹងគឺខ្ញុំដឹង ព្រោះខ្ញុំនៅចុងភូមិខាងត្បូង ភូមិជាមួយគ្នាប៉ុន្តែមិនដែលបានដើរសួរគ្នាទេសម័យនោះ ។

ធានី ៖ ចុះពេលលោកគ្រូធ្វើជាងដែកហ្នឹងដែលធ្លាប់ឮគេចាប់គេអី ឬក៏ធ្លាប់ឃើញ?

គុណ : ខ្ញុំចង់ជម្រាបជូនថា នៅពេលដែលខ្ញុំនៅជាងដែកហ្នឹងគឺនៅសុបិន្តហ្នឹង ថ្ងៃមួយនៅក្នុង ដើម ៨០ប្រហែលជាខែ១-២ ឬក៏ចុង៧៧ហ្នឹង កាលហ្នឹងមានពួកកន្សែងសយើងមកពីកម្ពុជាក្រោម អញ្ចឹងវារត់គេចផ្លូវទ័ពរួច ព្រោះទ័ពនៅតាមព្រំដែនខ្មែរក្រហម អញ្ចឹងចូលមកបាន ចូលមកគ្នា១៥០នាក់ អញ្ចឹងចូលមកដល់ក្បែរកន្លែងចៅហ្វាយស្រុកនៅសុបិន្តហ្នឹង គឺកន្លែងខ្ញុំជាងដែកហ្នឹងនៅសុបិន្តហ្នឹងដែរ អញ្ចឹងមកគឺវាមកពេលយប់ឡើងដាក់ត្នោតប្រជាជនហូប ដល់ពេលនោះគេថាគេសុំជួប ខៀវ សំផន តែខ្ញុំមិនដឹងដែរណា៎ អញ្ចឹងពេលទៅខ្ញុំទៅ ឃើញទ័ពកន្សែងសហ្នឹង សុទ្ធតែកាំភ្លើងនៅពេញដៃ សុទ្ធតែអាការហើយចូលមកបាន ហើយនៅក្នុងមានស្ពី ឈ្លបគ្មានស្ពីទេ ពួកខ្មែរក្រហមនៅក្នុងនេះមានស្ពី ឈ្លបមានតែកាបីន មានអីការពារហ្នឹង អញ្ចឹងអត់ហ៊ានអញ្ចឹងទៅរាយការណ៍ប្រាប់គាត់ំ ហើយនឹងយាយបូ អញ្ចឹងគាត់ឲ្យក្រោមឪវាទរបស់គាត់មកលួង អញ្ចឹងក្នុងនោះមានខាងកសិកម្ម ពានិជ្ជកម្មគេ មកលួងឲ្យគាត់នៅសម្រួលឥរិយាបទ គេកាប់គោ កាប់ជ្រូកជប់លៀងឲ្យ អញ្ចឹងជប់លៀង ហើយគេថាមិនអីទេ អញ្ចឹងមិនបាច់ដើរទៅវែងឆ្ងាយទេ អញ្ចឹងនៅសម្រាកនៅហ្នឹង ចាំគេយកឡានដឹកឲ្យបានទៅជួបខៀវ សំផន។

ផានី : ហើយកាលហ្នឹងលោកគ្រូនៅក្បែរហ្នឹង បានឃើញហេតុការអស់ហ្នឹង ហើយដឹងគេរកអី អញ្ចឹងដែរ លោកគ្រូជួយគេដែរ?

គុណ : អត់ទេ ខ្ញុំនៅជាងដែកហ្នឹង ដល់ពេលថ្ងៃល្ងាចសម្រាកហើយ ពេលហូបបាយអីយើងអាច ដើរមកបាន ព្រោះម៉ោងពិតរបស់គេណាស់។

ផានី : ចុះម៉េចបានជាលោកគ្រូដឹងរឿងហ្នឹង?

គុណ : ព្រោះខ្មែរ ហើយគេនិយាយខ្មែរដែរ។

ផានី : គាត់ហ្នឹងមកពីកម្ពុជាក្រោម?

គុណ : មកពីកម្ពុជាក្រោម។

ផានី : ប៉ុន្មាននាក់ដែរលោកគ្រូ?

គុណ : កាលមកហ្នឹងជាង១០០ តែខ្ញុំមិនប្រាកដថា១០០ប៉ុន្មានទេ បើសួរគាត់ទៅគាត់ថាមកជាង ១០០នាក់ មកច្រើនណែនហ្នង។

ផានី : គាត់មានប្រាប់ថាគាត់ឈ្មោះអីទេលោកគ្រូ?

គុណ : អត់មានហ៊ានសួរគាត់ឈ្មោះអីទេ។

ផានី : គ្រាន់តែគេប្រាប់ប៉ុណ្ណឹង?

គុណ :　បាទ! ប្រាប់ប៉ុណ្ណឹង អញ្ចឹងពេលហើយលួងដកអាវុធចេញអស់ ដកចេញអស់មកយកដាក់នៅសាលាស្រុកគេនៅសុបិន្តនេះដែរណា៎ អញ្ចឹងពេលដែលយកទៅហ្នឹង ដែនការហ្នឹងខ្ញុំដឹងតែយកគាត់ទៅសម្លាប់ហើយពួកអស់ហ្នឹង ព្រោះអញ្ចេះ ឮស្នូរតែស្នូរកាំភ្លើង ព្រោះកាលហ្នឹងគេយកឡានយើងអាស៊ីបទាហានហ្នឹង ដឹកបាន៥-៦នាក់ចុះអាហ្នឹង អញ្ចឹងឲ្យឡើងទៅម្តង៥-៦នាក់ គេគឺគេរៀបចំកន្លែងគេហើយទៅតាមដែលខ្ញុំឮសម្លេងគេបាញ់ហ្នឹងនៅបៀតគុកវត្តប្រធាតុ ប្រធាតុយើងនេះកន្លែងគុកជំនាន់ប៉ុល ពត កន្លែងគុកហ្នឹងហ្នង ហើយកន្លែងហ្នឹងក្រោយមកខ្ញុំបាន　　ពេលដែលខ្ញុំធ្វើគ្រូបង្រៀនខ្ញុំបាននាំសិស្សទៅប្រម៉ែលប្រមូលអដ្ឋិធាតុទៅដាក់នៅក្នុងចេតិយ ។

ធានី :　លោកគ្រូបានចូលរួមដែរ?

គុណ :　បាទ! បានចូលរួម ពេលឃើញចេញបានមួយហ្នឹងទៅ ង៉ឹងៗបាត់ ដល់បាត់អញ្ចឹងពីវត្តប្រធាតុហើយនឹងវត្តសុបិន្តហ្នឹងវានៅភូមិអញ្ចេះ　យើងអាចមើលឃើញកំពូលព្រះវិហារឃើញ ហើយស្នូរកាំភ្លើងអាចស្តាប់បាន បានបន្តិចឮស្នូរព្រលគេសម្លាប់ ហើយខ្ញុំថាអ៎! យកពួកហ្នឹងទៅសម្លាប់ហើយ អញ្ចឹងស្អែកឡើង មួយថ្ងៃហ្នឹងវាដឹក៣-៤ដង ប៉ុន្តែវាយកផ្លូវផ្សេងៗគ្នា ។

ធានី :　ប៉ុន្តែទៅវត្តហ្នឹងដដែល?

គុណ :　បាទ! តែផ្លូវផ្សេងៗគ្នា ។

ធានី :　ខាងណាគេអ្នកប្រាប់ ឬមួយខាងណាគេអ្នកបញ្ជាឲ្យមានការដឹកអញ្ចឹងលោកគ្រូ?

គុណ :　ចៅហ្វាយស្រុកគេហ្នឹងហ្នង ឬក៏ខាងអគ្គការគេ ព្រោះកាលណាតែចូលមកអញ្ចឹងគេរាយការទៅថ្នាក់លើទៀតណា៎ ប៉ុន្តែមិនដឹងជាថ្នាក់លើគេហ្នឹងអ្នកណាជាអ្នកបញ្ជា ខ្ញុំមិនអាចដឹងទេ ប៉ុន្តែគ្រាន់តែដឹងថាក្នុងស្រុកហ្នឹងខ្ញុំស្គាល់ចៅហ្វាយស្រុក ដូចខ្ញុំប្រាប់ប្អូនអញ្ចឹងថា មានតាតុំហ្នឹងប្រធាន បន្ទាប់មកតាទិត តាទិតហើយយាយបូហ្នឹង ។

ធានី :　តាតុំប្រធានធំ ។

គុណ :　បាទ! គាត់ប្រធានគេហ្នឹង ។

ធានី :　ចុះលោកគ្រូដល់ឃើញគាត់មក ហើយពួកគាត់ហ្នឹងស្លៀកពាក់ជាទាហានឬក៏ម៉េច?

គុណ :　ទាហានហ្នង ខោអាវប៉ារ៉ាហ្នង ។ ។

ធានី :　ទាហានខាងណាដែរ?

គុណ :　បើតាមមើលគាត់មិនដឹងជាខាងណាទេ ខ្ញុំឃើញគាត់មកគេថាគាត់កន្សែងសៗអញ្ចឹងហ្នង ។

ធានី ៖ គេហៅទាហានកន្ទេងស?

គុណ ៖ បាទ! ទាហានកន្ទេងស ពួកគាត់មកពីក្រោមមក ខ្ញុំជួបព្រឹត្តិការណ៍ហ្នឹងនៅសម័យហ្នឹង កាលខ្ញុំនៅជាងដែកហ្នឹង អាហ្នឹងចុងវៀតណាមបុកដេញដូចខ្ញុំថាអញ្ចឹងណា៎ ដល់ហើយទៅ ជាងគេហៅយកទៅជួយ ហើយដល់វៀតណាមទៅស្រុកលើកទី១ហ្នឹងទៅ លើកទី២បុកទៅ ខ្ញុំមកតាមព្រំដែនហ្នឹងទៅ ។

ធានី ៖ អញ្ចឹងកាលពេលលោកគ្រូទៅជួយទ័ពហ្នឹងទៅ អត់មានបានហាត់ទាហានហាត់អីទេ?

គុណ ៖ អត់មានបានហាត់ទេ មិនដឹងកាំភ្លើងកាច់កែម៉េចផង អ្នកដែលទៅមុនដំបូងមិនដឹងថាបាញ់ យ៉ាងម៉េច មិនចេះបាញ់ អញ្ចឹងគេឲ្យយើងជួយជញ្ជូនបាយទឹក ។

ធានី ៖ នៅសមរភូមិណាដែរ?

គុណ ៖ នៅជាក្តីយើងនេះ ជាក្តីនៅខាងត្បូងគិរីវង់ ។

ធានី ៖ នៅភូមិឃុំអីដែរ?

គុណ ៖ ជាក្តីហ្នឹងនៅក្នុងឃុំតាអូរ ។

ធានី ៖ ស្រុកគិរីវង់ដែរ?

គុណ ៖ បាទ! ស្រុកគិរីវង់ដែរ ។

ធានី ៖ ខាងណាអ្នកបញ្ជាឲ្យលោកគ្រូទៅដែរកាលហ្នឹង?

គុណ ៖ ចៅហ្វាយស្រុក ។

ធានី ៖ ចៅហ្វាយស្រុកហ្នង?

គុណ ៖ គេសុំជាងដែកហ្នង គេថាសុំទៅជួយទ័ព ទៅជួយវ៉ៃវៀតណាម អញ្ចឹងទៅទាំងអស់ទុកតែ តា ៗ ទេ តាដែលចំណាស់ ៗ ។

ធានី ៖ មូលហេតុអីបានជាគេទៅវ៉ៃនៅទល់ដែនហ្នឹង?

គុណ ៖ កាលហ្នឹងគេថាវៀតណាមឈ្លានពាន យៀកកុង ខ្មែរក្រហមវាប្រកាន់ណាស់យៀកកុង ។

ធានី ៖ ឆ្នាំ៧៨ហ្នឹង?

គុណ ៖ បាទ!

ធានី ៖ ចុះលោកគ្រូបាននិយាយថាវត្តប្រធាតុ លោកគ្រូមានបានដឹងរឿងអីខ្លះនៅវត្តប្រធាតុហ្នឹង ទេ?

គុណ ៖ វត្តប្រធាតុហ្នឹងកាលជំនាន់សម័យប៉ុល ពត គឺកន្លែងគុកមួយ ។

ធានី ៖ ហេតុអីបានជាលោកគ្រូដឹងថាជាកន្លែងគុក?

គុណ : ព្រោះកាលហ្នឹងបានខ្ញុំដឹង ព្រោះខ្ញុំធ្វើជាងដែកហ្នឹងគឺសម័យហ្នឹងគឺគុកវាមាន២កន្លែងក្នុងស្រុក មុនដំបូងនៅឃុំគោកព្រិចយើងនេះ ក្រោយមកបានគេផ្លាស់កន្លែងហ្នឹងទៅ ទៅធ្វើនៅវត្តប្រធាតុ ។

ធានី : អញ្ចឹងគោកព្រិចហ្នឹងដំបូងនៅឆ្នាំណាដែរលោកគ្រូ ហើយបានគេទៅវត្តប្រធាតុ?

គុណ : គោកព្រិចហ្នឹងតាំងពីចាប់កើតគុកកន្លែងឃុំឃាំងអ្នកទោសហ្នឹងគឺនៅឆ្នាំ១៩៧៥-៧៦ហ្នឹង ។

ធានី : ៧៥-៧៦?

គុណ : បាទ!

ធានី : ដល់ពេលវត្តប្រធាតុលោកគ្រូ?

គុណ : វត្តប្រធាតុហ្នឹងបើតាមមើល អាគុកនៅកន្លែងនេះ អាគុកនៅគោកព្រិចនេះប្រហែលជាគុកហ្នឹងមានទោសស្រាលទេ ហើយប្រធាតុហ្នឹងប្រហែលជាទោសធ្ងន់ ។

ធានី : អញ្ចឹងទាំងពីរហ្នឹងមានយូហើយ?

គុណ : បាទ! មានយូហើយ ប៉ុន្តែឆ្អឹងដែលស្លាប់ច្រើនគេយកទៅដាក់ហ្នឹងគឺវត្តប្រធាតុហ្នឹងច្រើនជាងគេ ។

ធានី : ហើយលោកគ្រូដឹងថាអ្នកណាគេជាប្រធាននៅហ្នឹងទេ?

គុណ : កន្លែងគុកហ្នឹងខ្ញុំមិនបានដឹងថាអ្នកណាមេទេ មិនដឹងអ្នកណាជាអ្នកគ្រប់គ្រងទេ ព្រោះជួនឃើញមេឃុំគេក៏មាននៅហ្នឹងដែរ អ្នកយាមគុកគេកន្លែងនោះក៏ខ្ញុំមិនដែលបានចូលដែរ មិនយើងណាដើរបានទេ ។

ធានី : ចុះ តាញ៉ែត?

គុណ : តាញ៉ែត ហ្នឹងគឺនៅឃុំកំពែងនេះទេ ដោយឡែកឃុំកំពែងគ្មានកន្លែងគុកទេ អត់មានគុកទេ ។

ធានី : ចុះលោកគ្រូមេញនិយាយថា មានឃុំគេនៅប្រធាតុហ្នឹងដែរ ឃុំខាងណាវិញ?

គុណ : ប្រធាតុនោះនៅក្នុងឃុំគោកព្រិចដែរ ប៉ុន្តែនៅខាងកើតភ្នំ ។

ធានី : ភ្នំអីគេ?

គុណ : ភ្នំហ្នឹងគេហៅភ្នំស្វែង ។

ធានី : ខាងកើតភ្នំស្វែងហ្នឹង?

គុណ : បាទ!

ធានី : ចុះលោកគ្រូដែលធ្លាប់ឃើញអ្នកណាដែលរួចទោសពីវត្តប្រធាតុហ្នឹងនៅរស់ដល់រាល់ថ្ងៃទេ?

គុណ : មានមេឃុំកំពែងហ្នឹង ។

ធានី ៖ មេឃុំ?

គុណ ៖ បាទ! បងអៀល គាត់បានជាប់នៅកន្លែងហ្នឹង ហើយគាត់បានរួចខ្លួន ប៉ុន្តែគាត់ត្រូវទទួលមរណៈភាពហើយ គាត់បានធ្វើមេឃុំហើយស្លាប់ប៉ុន្មានឆ្នាំ ២-៣ឆ្នាំហើយ ។

ធានី ៖ ស្លាប់ឆ្នាំប៉ុន្មានដែរលោកគ្រូ?

គុណ ៖ បងអៀល គាត់បានបោះឆ្នោតហើយកាលហ្នឹង យើងគិតមើលទៅ ព្រោះយើងបោះឆ្នោតឆ្នាំ៩៣ អ៊ឺ! ស្លាប់មុន៩៣ ព្រោះ៩៣យើងបោះឆ្នោតហើយ ៩៣បោះជាប់មេឃុំ ភាងហើយហ្នឹង ។

ធានី ៖ អញ្ចឹងគាត់ស្លាប់មុន៩៣?

គុណ ៖ បាទ! គាត់មកធ្វើមេឃុំហ្នឹង ប៉ុន្តែដល់ពេលគេឈប់បោះឆ្នោតគាត់ឈឺ ។

ធានី ៖ អញ្ចឹងនៅ៩៣ដែរហ្នឹងលោកគ្រូ គ្រាន់ថាដើម៩៣ឬក៏?

គុណ ៖ អាហ្នឹងនៅក្នុងឆ្នាំ៩៣ហ្នឹងគាត់ចាប់ឈឺ ហើយគាត់ឈប់ធ្វើមេឃុំទៅ ដល់ឈប់ធ្វើមេឃុំគេលើកតំណាង លើកតំណាងគាត់មក អញ្ចឹងគាត់ជាប់ឆ្នោតទល់រាល់ថ្ងៃហ្នឹងមក ។

ធានី ៖ ប៉ុន្តែគាត់ស្លាប់ឆ្នាំប៉ុន្មានដែរមើលទៅ?

គុណ ៖ ប្រហែលជាខ្ទង់៩២-៩៣ហ្នឹងបង ព្រោះយើងបោះឆ្នោតហើយមានមេឃុំថ្មី គាត់ឈឺលើសឈាមញញាក់ញញ័រធ្វើអីអត់កើត អាហ្នឹងគាត់ជួបនៅកន្លែងហ្នឹងហើយ គាត់បានរួចខ្លួននៅកន្លែងហ្នឹងហើយ ។

ធានី ៖ ហេតុអីបានជាគាត់ជាប់ទោសនៅហ្នឹង?

គុណ ៖ ជំនាន់នោះអត់ដឹងដែរ ព្រោះគាត់ចំណាស់ជាងខ្ញុំ មិនដឹងជាកំហុសគាត់មកពីមូលហេតុអីខ្ញុំក៏អត់បានដឹងដែរ ។

ធានី ៖ ចុះក្រៅពីគាត់មានអ្នកផ្សេងទៀតដែលនៅរស់ទេ?

គុណ ៖ នៅវត្តប្រធាតុហ្នឹងមាន អ៊ឺ! ឈប់ នៅយើងនេះគ្មានទេ អត់មានឃើញទេ ឃើញតែបងអៀលហ្នឹងបានរួច អញ្ចឹងបានខ្ញុំថាស្គាល់គាត់ គាត់ហ្នឹងបើនិយាយពីប្រវត្តក្នុងគុកហ្នឹងគាត់ដឹង អញ្ចឹងយើងមិនអាចដឹងបាន ។

ធានី ៖ អញ្ចឹងលោកគ្រូ ពេលដែលលោកគ្រូថាលោកគ្រូធ្វើជាងដែកហ្នឹង គេឲ្យលោកគ្រូធ្វើជាសម្ភារៈអីខ្លះ កាលធ្វើជាងដែកហ្នឹង?

គុណ ៖ ពេលនោះគេឲ្យយើងធ្វើឲ្យមើល របៀបថាស្នូរដែរ ធ្វើឡសម្រាប់ធ្វើដែក អញ្ចឹងឡស្នូរដែកនៅក្នុងខេត្តគេធ្វើធំ ដល់ពេលខ្ញុំយកមកច្នៃនៅនេះ ខ្ញុំយកលួសបន្តគ្នាទៅហើយបិទដី

ដំបូកប្រឡោះកណ្តាលទៅធ្វើសម្រាប់បង្ហូរទឹកដែកមកក្រោមវិញមក ហើយធ្វើសម្រាប់ខ្ទាបទឹកដែករលាយសម្រាប់ទាញបង្ហូរទឹកដែកចូលពុម្ព អញ្ចឹងខ្ញុំធ្វើអាហ្នឹងវាអត់ប្រសិទ្ធភាព វាទៅអត់រួច វាអានោះគេកម្លាំងម៉ាស៊ីន ហើយយើងអត់មានម៉ាស៊ីន ពេលដែលបញ្ចេះភ្លើងយើងដាក់នឹងដើង ដាក់ដើម្បីឲ្យដែករលាយ ហើយគេនោះម៉ាស៊ីនវ៉ូហ្វងហ្នឹង ដែកសម្រាប់ស្ងួរដាលវាកម្ដៅធ្ងន់ជាងដែកដេរ៉ា ដែកដេរ៉ាយើងដាក់ដុតតែខុសយើងក៏រលាយបងមើលតែឆ្នាំងបាយយើងពេលរីងទឹកហ្នឹង យើងដុតភ្លើងខ្លាំងគឺឆ្ងាយគូទហើយ ហើយអាដែកដាលយើងគឺយកក្បាលម៉ាស៊ីនឡានចាស់ៗ ក្បាលយន្តដេរ យកមកវ៉ៃកំទេចដុំៗហើយដាក់ពុម្ព ពុម្ពហ្នឹងពុម្ពដី ហើយភ្ជាប់ពុម្ពដាលពីលើមកអញ្ចេះមក អានេះវាពីក្រោម ដល់ពេលដែករលាយយើងផ្ទាវអានេះវិញឲ្យហូរចូលពុម្ពដាល ។

ធានី : អញ្ចឹងលោកគ្រូធ្វើហ្នឹងធ្វើតែដាល?

គុណ : បាទ! ដាល ឆ្នាំង ខ្ទះ ហើយនឹងស្នាបព្រា ។

ធានី : មានតែប៉ុណ្ណឹងទេលោកគ្រូ អត់មានអីផ្សេងទៀតទេ?

គុណ : បាទ! អត់មានទេ ។

ធានី : ចុះដូចជាកាំបិតអីហ្នឹង?

គុណ : កាំបិតជាងដែក ជាងដែកនៅជាមួយគ្នាហ្នឹងដែរ ជាងដែក ជាងកាំបិត ជាងពូថៅ ជាងខ្វាង ។

ធានី : អាហ្នឹងផ្សេងៗទៀត?

គុណ : ផ្សេងទៀត ។

ធានី : អញ្ចឹងលោកគ្រូបានតែចាក់ឆ្នាំង?

គុណ : ចាក់ឆ្នាំង ដល់ពេលអស់ដែកដេរ៉ាគេហៅយើងជួយសប់ស្នប់អញ្ចឹងទៅ ជួយកាន់អាញ្ញូវ៉ៃដែកអីដែរ ។

ធានី : រហូតដល់បែកទៅបានលោកគ្រូទៅធ្វើទ័ពធ្វើអីហ្នឹងទៅ?

គុណ : បាទ! ធ្វើទ័ព ។

ធានី : ទៅធ្វើទ័ពហ្នឹងដូចថាអ្នកណា គេមានដូចថាជាមេជាកើយ?

គុណ : កាលហ្នឹងមិនទាន់ក្តាប់អីបានច្បាស់ផង ប៉ុន្តែស្គាល់មេក្រុមគេ យើងមិនទាន់ដឹងកងពលប៉ុន្មានអីប៉ុន្មាន វរៈប៉ុន្មានផង ។

ធានី : អញ្ចឹងលោកគ្រូពេលដែលនៅធ្វើជាងដែកហ្នឹង លោកគ្រូធ្វើជាអីគេ?

គុណ ៖ ខ្ញុំកាលហ្នឹងគេឲ្យធ្វើមេជាងដែរ ។

ធានី ៖ មេជាង?

គុណ ៖ បាទ!

ធានី ៖ ហើយខាងណាអ្នកគ្រប់គ្រងលោកគ្រូដែរ?

គុណ ៖ អាហ្នឹងគឺស្រុកគេ ក្នុងមេជាងមានស្រុក អញ្ចឹងផ្នែកមេជាងហ្នឹងវាមានផ្នែកមេជាងដើម្បីជាងខាងឆ្នាំងណា៎ អញ្ចឹងឆ្នាំងហ្នឹងខ្ញុំមានកម្មករ មាននារី មានយុទ្ធជន៧-៨នាក់ដែរ ។

ធានី ៖ ៧នាក់លោកគ្រូ?

គុណ ៖ បាទ! ៧នាក់ ។

ធានី ៖ ៧នាក់ហ្នឹងស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

គុណ ៖ ៧នាក់ហ្នឹងមាន ស្រី៤នាក់ ។

ធានី ៖ អញ្ចឹងស្រី៤នាក់ ប្រុស៣?

គុណ ៖ បាទ!

ធានី ៖ ស្រីៗហ្នឹងគាត់ឲ្យធ្វើអីគេដែរលោកគ្រូ?

គុណ ៖ ឲ្យជួយធ្វើពុម្ព ។

ធានី ៖ ជួយធ្វើពុម្ពដីហ្នឹង?

គុណ ៖ បាទ! ធ្វើពុម្ពដី ជួយធ្វើពុម្ព ជួយរែងដីឲ្យវាម៉ត់ទៅហើយយកមកធ្វើពុម្ពទៅណា៎ ។

ធានី ៖ អញ្ចឹងលោកគ្រូគ្រប់គ្រងពួកគាត់ផ្ទាល់?

គុណ ៖ បាទ! អាហ្នឹងគ្នាខាងដែកហ្នឹងគឺខ្ញុំមើលអញ្ចឹងទៅ ហើយខាងអ្នកដុំកាំបិតពូថៅមានមេជាងគេមួយអញ្ចឹងទៅ ។

ធានី ៖ ប៉ុន្តែខាងណាអ្នកគ្រប់គ្រងលោកគ្រូបន្តទៀត?

គុណ ៖ អាហ្នឹងគឺ តាអំ ។

ធានី ៖ តាអំ?

គុណ ៖ បាទ! ឈ្មោះគេ អំ ។

ធានី ៖ តាអំ ហ្នឹងជាអ្នកណាគេលោកគ្រូ?

គុណ ៖ តាអំ ហ្នឹងគាត់ជាមេគ្រប់គ្រងប្រចាំស្រុកហ្នឹងហ្នង ។

ធានី ៖ គាត់កាន់ស្រុកហ្នឹង?

គុណ ៖ បាទ! គាត់កាន់ស្រុក ។

ធានី ៖	រាល់ថ្ងៃគាត់នៅរស់ទេលោកគ្រូ?

គុណា ៖	រាល់ថ្ងៃគាត់នៅរស់ ។

ធានី ៖	នៅណាវិញលោកគ្រូ?

គុណា ៖	នៅឃុំព្រៃអំពក សព្វថ្ងៃគាត់នៅហ្នឹង ។

ធានី ៖	ហើយគាត់ឈ្មោះអីគេ អំ?

គុណា ៖	ដូចជាស្អី អំ ទេ ដឹងតែឪពុកគាត់ឈ្មោះ លុក ឪពុកគាត់ឈ្មោះគុង លុក តែគាត់មិនដឹង ដាក់ជីតាអី ដាក់លុក អំ អញ្ចឹងហ្នងទៅ អាហ្នឹងឪពុកគាត់ទេ តែខ្ញុំមិនដឹងឈ្មោះអីទេ ព្រោះគាត់ប្រាប់ខ្ញុំថាឪពុកគាត់ឈ្មោះគុង លុក ។

ធានី ៖	ហើយម្ដាយគាត់ឈ្មោះអីដែរលោកគ្រូ?

គុណា ៖	ប្រពន្ធគាត់មែន?

ធានី ៖	ប្រពន្ធគុង លុក ហ្នឹង?

គុណា ៖	អត់ចាំទេ ។

ធានី ៖	ចុះប្រពន្ធគាត់?

គុណា ៖	ប្រពន្ធគាត់ស្លាប់ហើយ ។

ធានី ៖	ឈ្មោះអីដែរប្រពន្ធគាត់ហ្នឹង?

គុណា ៖	ប្រពន្ធគាត់ខ្ញុំអត់ចាំឈ្មោះដែរហ្នឹង ។

ធានី ៖	គាត់នៅភូមិអីដែរ លោកគ្រូចាំទេ?

គុណា ៖	គាត់នៅភូមិជ្រោយ ។

ធានី ៖	ភូមិជ្រោយ?

គុណា ៖	បាទ! ភូមិជ្រោយ ឃុំព្រៃកំពក ។

ធានី ៖	គាត់នៅរស់ទេរាល់ថ្ងៃ?

គុណា ៖	សព្វថ្ងៃគាត់នៅរស់ទេ ។

ធានី ៖	អញ្ចឹងលោកគ្រូ ពេលដែលលោកគ្រូធ្វើការជាងដែកអញ្ចឹង តើធ្លាប់ដែលឃើញឬក៏មាន បញ្ហាពីណាឲ្យធ្វើការអីមួយមានទេ ដូចថាគេឲ្យធ្វើអីផ្សេងៗក្រៅពីជាងដែក?

គុណា ៖	អត់មានទេ មិនដែលបានធ្វើអីទេ អត់ដែលបានធ្វើអី គ្រប់គ្រងអីក៏មិនដែលបាន ។

ធានី ៖	ចុះលោកគ្រូ ដូចថាក្នុងនាមលោកគ្រូជាមេក្រុមមេអីអញ្ចឹង ដែលធ្លាប់បានជួយអ្នកណាឲ្យ រួចរស់ជីវិតឬក៏ជួយផ្ដល់ជាអាហារដល់ពួកគាត់ទេ?

គុណ ៖ ដែលកាលខ្ញុំនៅលោក កាលនៅលោកបានជួយ ។

ធានី ៖ បានជួយអ្នកណាដែរ?

គុណ ៖ បានជួយគេម្នាក់ខាងភូមិត្បូងវត្តនេះណា៎ ដល់ក្រោយមកទៀតយកមកម្នាក់ទៀត តាមមកទៀត ចុះយកមកតាមផ្លូវហ្នឹង អាហ្នឹងគេចាប់មកដល់វត្តហើយ សុំបិណ្ឌបាត្រគេបាន គេលើកលែងឲ្យដោយសារ ហើយម្យ៉ាងទៀតប្រជាជននៅភូមិជាប់វត្តហ្នឹង ដូចអូននៅភូមិហ្នឹង ប៉ុន្តែប្អូនស្រីនេះភូមិជាមួយអាអូន អញ្ចឹងដល់ពេលអូនរត់មក គេគុណអើយជួយបិណ្ឌបាត្រឲ្យផងគេចាប់ប្អូនករុណាហើយ អញ្ចឹងបបួលចៅអធិការទៅបិណ្ឌបាត្រយកមកវិញមក ។

ធានី ៖ ឈ្មោះអីគេលោកគ្រូ?

គុណ ៖ ភ្លេចហើយខ្ញុំ មិនស្គាល់ទេ ។

ធានី ៖ តែម្នាក់ហ្នឹងទេ ចុះម្នាក់ទៀត?

គុណ ៖ ដល់ក្រោយម្នាក់ទៀតយកមកដល់អញ្ចឹង គាត់រត់មកទៀត អាហ្នឹងគាត់នៅភូមិជាមួយគ្នាហ្នឹង ប៉ុន្តែម្នាក់ហ្នឹងគេធ្លាប់ធ្វើទាហាន អញ្ចឹងដល់ពេលមកដល់ ខ្ញុំទៅពេលទៅដល់គេចាប់គាត់បណ្តើរយកទៅសម្លាប់ហើយ ចងមុខហើយអាហ្នឹង ចងមុខគាត់ចងដៃ ទៅដល់ឃើញព្រឹសម្បុរគឺងគក់ដែរ ភ័យដែរ ដល់ពេលអញ្ចឹងសុំគេថា អាហ្នឹងអ្នកចាប់គេហ្នឹងឈ្មោះផុងអាអ្នកបណ្តើរគាត់ហ្នឹង ដល់ពេលអញ្ចឹងគេថាគេគុណមកធ្វើអី ហើយខ្ញុំថាអាត្មាមកចង់សុំបិណ្ឌបាត្រ បើចង់បិណ្ឌបាត្រតោះទៅជាមួយករុណា ឮថាតោះទៅជាមួយករុណា នឹកឃើញពីក្រោយនោះវាព្រលប់ យើងព្រិលៗមើលគ្នាអត់ស្គាល់ទេណា៎ មានដឹបងមានអីទៅហើយ ដល់ហើយមិនកើតទេ គេគុណយើងនិមន្តថយ មិនកើតទេ ។

ធានី ៖ អញ្ចឹងអត់បានបិណ្ឌបាត្រគាត់?

គុណ ៖ អត់បាន សុំបិណ្ឌ គេថាបើចង់បិណ្ឌទៅតាមគេ ដល់អញ្ចឹងអត់ហ៊ានទៅ ព្រោះគេបណ្តើរទៅហើយ អញ្ចឹងក្រោយមកក៏គេយកទៅ យកទៅសម្លាប់នៅវត្តខ្ញុំបង្រៀនរាល់ថ្ងៃនេះ ខាងកើតវត្តហ្នឹង ។

ធានី ៖ អញ្ចឹងលោកគ្រូ ពេលដែលលោកគ្រូនៅធ្វើជាជាងដែកនៅស្រុកហ្នឹង ស្រុកយើងហ្នឹងនៅទីតាំងកន្លែងណាដែរ?

គុណ ៖ នៅគិរីវង់ហ្នឹងហ្មង ។

ធានី ៖ នៅគិរីវង់កន្លែងណាដែរ?

គុណ ៖ នៅខាងកើតផ្សារគិរីវង់ ។

ធានី ៖ ហើយចុះដែលថាមន្ទីររបស់ស្រុកហ្នឹងនៅខាងណាវិញទៅ?

គុណ ៖ មន្ទីរស្រុកគាសៀង អាហ្នឹងចុងក្រោយហ្នឹងគឺគាត់នៅគិរីវង់ហ្នឹងដែរ ។

ធានី ៖ ចុះយាយបូ?

គុណ ៖ យាយបូ ហ្នឹងមុនដំបូងនៅឃុំគោកព្រិចនេះ ចេញពីគោកព្រិចយើងមកនៅសុបិន្ត អញ្ចឹង សុបិន្តហ្នឹងហើយមានមួយទៀតគឺត្រពាំងរន្ធ ។

ធានី ៖ អញ្ចឹងផ្លាស់ប្តូរគ្នារហូត?

គុណ ៖ បាទ! កន្លែងគេពាហ្នឹងគឺគេចល័តចុះឡើងហ្នឹង ដូនកាលតាគុំ ហ្នឹងនៅកន្លែងហ្នឹង ដូនយាយបូ ហ្នឹងនៅកន្លែងហ្នឹង ព្រោះទាំង៣នាក់ហ្នឹងគេមើលកន្លែងហ្នឹងទៅវិញទៅមកអញ្ចឹងណា៎ ។

ធានី ៖ ចុះយាយបូ ហ្នឹងមេញលោកគ្រូថាគាត់នៅរស់ តើគាត់រស់នៅកន្លែងណាដែរ លោកគ្រូដឹងទេ?

គុណ ៖ ដល់ពេលរត់ទៅលើ វាបែកវៀតណាមបុកមកហ្នឹង វាឲ្យរត់ទៅលើ រត់ទៅលើហ្នឹងជួបប្រជាជន ព្រោះប្រជាជនមួយស្រុកហ្នឹងគ្មានអ្នកណា...អ្នកណាក៏ស្គាល់ដែរ ។

ធានី ៖ ហើយចុះលោកគ្រូ ដូចថាពេលហ្នឹងមិនលោកគ្រូនិយាយថា តាញ៉ែត ហ្នឹងគាត់ខូចសិលធម៌ច្រើនណាស់ជាមួយនារីនៅក្នុងភូមិ ហើយម៉េចបានជាគេចាប់គាត់អញ្ចឹងលោកគ្រូ?

គុណ ៖ ព្រោះផ្នែកសិលធម៌គឺខ្មែរក្រហមតឹងតែងណាស់ ។

ធានី ៖ សិលធម៌ម៉េចទៅលោកគ្រូ?

គុណ ៖ សិលធម៌បានន័យថា ការខូចការជាមួយនារីភេទហ្នឹង ។

ធានី ៖ គាត់មានគ្រួសារហើយឬក៏នៅទេ?

គុណ ៖ តាញ៉ែត ហ្នឹងមានកូនកម្លោះក្រមុំហើយហ្នឹង ។

ធានី ៖ គាត់មានស្រុកកំណើតនៅណាដែរ?

គុណ ៖ គាត់នៅស្រុកត្រាំកក់ ។

ធានី ៖ ហើយម៉េចបានជាគេដឹងថាគាត់ហ្នឹងខូចសិលធម៌?

គុណ ៖ រហូតយកគាត់ដល់មានផ្ទៃពោះហើយហ្នឹង យកយាយហ្នឹងប្តីគាត់ហ្នឹងធ្វើជាងជាមួយខ្ញុំហ្នឹងធ្វើជាងដែកហ្នឹង ។

ធានី ៖ គាត់ឈ្មោះអីគេ?

គុណ ៖ ប្ដីរបស់គាត់ឈ្មោះ ញុញ ហើយយាយហ្នឹងឈ្មោះយាយរោក ចំណាស់ជាងប្រពន្ធរបស់ខ្ញុំទៀត ហើយយករហូតបានកូន១ កូនមួយបានបួសនៅវត្តហ្នឹងទើបយើងសម័យក្រោយហ្នឹង ប៉ុន្តែក្រោយមកឈឺស្លាប់ទៅកូនហ្នឹង ។

ធានី ៖ ប៉ុន្តែ តាញ៉ោត ហ្នឹងគាត់មានជាមួយលោកយាយហ្នឹងហើយ បានបែកការឬក៏ម៉េច?

គុណ ៖ ហ្នឹងហើយ បែកការគឺបែកការជាមួយលោកយាយហ្នឹងហ្នុង មានផែនការប្រុងរត់ទៅវៀតណាម យើងជិតបែកហើយហ្នឹង ។

ធានី ៖ ហើយលោកគ្រូដឹងថា ញ៉ោត ហ្នឹងគេធ្វើយ៉ាងម៉េចខ្លះចំពោះគាត់ទេ ពេលដែលគាត់ខុសសីលធម៌អញ្ចឹង?

គុណ ៖ ពេលនោះគឺខ្ញុំឃើញ តាតុំ ហ្នឹងគាត់យកទៅដោយខ្លួនឯង ព្រោះគាត់យកទៅសុបិន្ត កន្លែងបៀតជាងដែកខ្ញុំហ្នឹងណា៎ គាត់ចងដៃហើយដឹករទេះសេះទៅដល់ គាត់ថាឃើ! អាញ៉ោតអញស្រលាញ់ឯងស្មើរហ្នឹងកែវភ្នែកអញ ហើយឯងធ្វើគំនិតអញ្ចឹង គាត់ចាប់កន្លែងដើមទ្រូង គាត់ចាប់ចងហើយឲ្យអន្តុយអញ្ចឹង ហើយដួលផ្ងារអញ្ចឹង ដួលផ្ងារទៅក្រោយគេលើកឡើងវិញ ។

ធានី ៖ ហើយម៉េចទៀតទៅលោកគ្រូ?

គុណ ៖ ដល់ហើយយើងឃើញអញ្ចឹង យើងអត់ហ៊ាននៅមើលទេ ដល់អត់ហ៊ាននៅមើលអញ្ចឹងក៏មកកន្លែងវិញ ។

ធានី ៖ ចុះបន្ទាប់មកទៀតគេយកគាត់ទៅណា?

គុណ ៖ ញ៉ោត ហ្នឹងដល់ហើយដូចខ្ញុំនិយាយអញ្ចឹងថា គេដាក់ជាមួយខ្មែរយើង ព្រោះខ្មែរយើងកម្ពុជាក្រោមក៏រំដោះបានមកដែរ កាលសម័យហ្នឹងរត់មកហើយណា៎ អញ្ចឹងពេលហ្នឹងអ្នកដែលចប់មានចេះនិយាយភាសាវៀតណាមអីហ្នឹងគេថាខ្មែរកម្ពុជាក្រោម គេបញ្ជូនទៅហ្នុងគេបញ្ជូនទៅលើៗហ្នឹង មិនដឹងថាទៅណា ដូចខ្ញុំថាអញ្ចឹង ទៅលើហ្នឹងប្រហែលជាទៅខេត្តកំពតសំដៅទៅភ្នំដំរីរមៀលអញ្ចឹងណា៎ ហើយដឹក តាញ៉ោត ហ្នឹងទៅជាមួយឡានហ្នឹងដែរដាក់នៅមុខជាមួយតែកុងគេហើយចង ដល់ពេលឡើងឡានចងទីតាំងខ្ញុំឃើញចង អាហ្នឹងមេឃុំហ្នឹង ។

ធានី ៖ មិនមែននៅវត្តប្រធាតុយើងនេះទេ?

គុណ ៖ មិនមែនវត្តប្រធាតុទេ ។

ធានី ៖ ចុះខ្មែរកម្ពុជាក្រោមហ្នឹងគាត់មកពីណាបានមកដល់?

គុណ ៖ កាលនោះគឺខ្មែរក្រហមបុកចូលទៅហ្នឹងគេជម្លៀសមកខ្លះដែរ ។

ធានី ៖ បានប៉ុន្មាននាក់ដែរ?

គុណ ៖ ប្រជាជនច្រើនណាស់បង ។

ធានី ៖ ខ្មែរកម្ពុជាក្រោមដែលមកហ្នឹង?

គុណ ៖ បាទ! មកច្រើនណាស់ ហើយអ្នកដែលនៅខ្មែរយើង ព្រំដែនខ្មែរយើងដែលនៅម្តុំភ្នំដិនម្តុំអី ហ្នឹងគឺតែខ្មែរកម្ពុជាក្រោមទេ អញ្ចឹងដល់ពេលរំដោះអាចាប់នៅម្តុំភ្នំដិនទៅ អញ្ចឹងអ្នកអស់ហ្នឹងត្រូវឡើងមកលើ ។

ធានី ៖ មកតាមខ្មែរក្រហមទាំងអស់?

គុណ ៖ បាទ!

ធានី ៖ ហើយគេចាប់ទាំងអស់ហ្នឹងដែរ?

គុណ ៖ បាទ! យកទៅទាំងអស់ឲ្យតែនិយាយមិនច្បាស់ សួរទៅថាខ្មែរកម្ពុជាក្រោម ។

ធានី ៖ សួរទៅនិយាយមិនច្បាស់គឺយកទៅសម្លាប់?

គុណ ៖ បាទ!

ធានី ៖ តែមិនមែនយកទៅតំបន់២០៨ហ្នឹងទេ?

គុណ ៖ មិនមែនទេ?

ធានី ៖ ២០៨ហ្នឹងផ្សេងទៀតលោកគ្រូ?

គុណ ៖ ផ្សេងទៀត អាតំបន់ហ្នឹងគឺ ២០៨ហ្នឹងគឺឈ្មោះគេអ្នកដែល ឥឡូវមិនខ្វះទេអ្នកដែលនៅក្នុងភូមិខ្ញុំហ្នឹងគឺទៅ២០៨ហ្នឹង ។

ធានី ៖ ហើយម្តាយលោកគ្រូបានទៅដែរ?

គុណ ៖ បាទ! ម្តាយខ្ញុំក៏បានទៅ ហើយពូដែលនៅធ្វើទាហានហ្នឹងក៏បានទៅ ហើយជណ្តូងខ្ញុំមួយហ្នឹងក៏គាត់ធ្លាប់បានទៅដែរ ។

ធានី ៖ លោកគ្រូដឹងថាមូលហេតុអីបានជាគេចាប់ គាញ៉េត អាស់! ដឹងថាមូលហេតុអីបានជាគេបញ្ជូនខ្មែរកម្ពុជាក្រោមដែលជម្លៀសមកជាមួយកងទ័ពហ្នឹង គេបញ្ជូនទៅលើជាមួយគាញ៉េត ហ្នឹង?

គុណ ៖ អញ្ចេះ បើតាមដំណើរដែលផែនការគេត្រូវបញ្ជូនខ្មែរកម្ពុជាក្រោមហ្នឹងគឺគេមានផែនការគេហើយ គេត្រូវជម្លៀស ។

ធានី ៖ ហើយលោកគ្រូដែលធ្លាប់បានដឹងរឿងហ្នឹងទេ?

គុណ ៖ ខ្ញុំមិនដឹងថាតើស្រុក ឬក៏ខេត្ត ឬក៏តំបន់គេបញ្ជាឲ្យនេះអត់ ព្រោះឡានមក៤-៥គ្រឿង អញ្ចឹងមកដឹកឡើងទៅអញ្ចឹង ហើយតាញ៉ែត ពេលដែលចាប់ហើយហ្នឹង ដល់ហើយគេត្រូវបញ្ជូនទៅឲ្យថ្នាក់លើគេ អញ្ចឹងត្រូវធ្វើដំណើរទៅជាមួយឡានហ្នឹង មានឈ្លបគ្នកទៅអញ្ចឹងណាំ ។

ធានី ៖ តែលោកគ្រូមានបានឃើញជាលិខិតឬក៏ជាអីទេ ដែលថាត្រូវចាប់បញ្ជូនតាញ៉ែត ទៅ ត្រូវធ្វើម៉េចអីម៉េច?

គុណ ៖ លិខិតអត់បានឃើញទេ តែឃើញដាក់ឡានហ្នឹងដឹកទៅហ្នឹង អាហ្នឹងឃើញទៅ ប៉ុន្តែមិនដឹងជាយកទៅសម្លាប់ឬមួយក៏យកទៅដាក់ឃុំឃាំងទៀតខ្ញុំមិនអាចដឹងទេ ។

ធានី ៖ កាលហ្នឹងយាយបូ នៅកាន់កាប់?

គុណ ៖ កាលហ្នឹងតាគុំ ហើយនឹងយាយបូ នៅហ្នឹងដែរ ។

ធានី ៖ យាយបូ ហើយនឹងតាគុំ នៅហ្នឹងដែរពេលដែលចាប់ តាញ៉ែត ហ្នឹង?

គុណ ៖ បាទ! គាត់នៅហ្នឹងដែរ ។

ធានី ៖ ឆ្នាំប៉ុន្មានដែរលោកគ្រូ ដែលខ្មែរកម្ពុជាក្រោមវៃហើយសម្រុកមកវិញ?

គុណ ៖ ចាំខ្ញុំនឹកមើលសិន យូពេកហើយបង គិតទៅវាភ្លេចហើយ ប្រហែលជាចុង៧/៦អីហ្នឹង ព្រោះខ្ញុំផ្លាស់ទៅសុបិន្តហើយ ។

ធានី ៖ ចុះលោកគ្រូ តាំងពីលោកគ្រូធ្វើការមក លោកគ្រូមានដែលឮឈ្មោះមេដឹកនាំធំៗកាលសម័យខ្មែរក្រហម គាត់ចុះមកមើលឬក៏ធ្លាប់ឮថាគាត់ធ្វើអីៗទេ?

គុណ ៖ ពេលដែលខ្ញុំរស់នៅកាលហ្នឹង យើងនិយាយពីអ្នកធំៗដែលខ្ញុំបានចាំដូចខ្ញុំជម្រាបប្អូនអញ្ចឹងកាលនៅចិញ្ចឹមសត្វគឺបានទៅរៀននៅលើ គេហៅទៅរៀននៅលើហ្នឹងគឺបានស្គាល់សុនសេន ហ្នឹង ហើយក្រោយមកស្គាល់តាមុត ហើយដល់យើងចុះមកវិញក្រោយមកទៀតនេះ ត្រលប់មកវិញហ្នឹងគឺ កាលតាគុំ យាយបូ ហ្នឹង តាទិត ហើយក្រោយនេះតាសៀងចៅហ្វាយស្រុកចុងក្រោយ ។

ធានី ៖ តែប៉ុណ្ណឹងអត់មានទៀតទេ?

គុណ ៖ បាទ! អត់បានស្គាល់ទេ ។

ធានី ៖ ចុះតាសៀង ហ្នឹងគាត់មានស្រុកកំណើតនៅណាដែរ?

គុណ ៖ តាសៀង ហ្នឹងមកពីត្រាំកក់ គាត់មកពីត្រាំកក់ដែរ ។

ធានី ៖ ចុះតាគុំ, យាយបូ, តាទិត?

គុណ ៖ យាយបូហ្នឹងមិនមែនកំណើតនៅគិរីវង់យើងហ្នឹងដែរ ។

ធានី ៖ នៅណាវិញអញ្ចឹង?

គុណ ៖ យាយបូ ហ្នឹងមកពីត្រាំកក់ដែរ ច្រើនតែត្រាំកក់ទេមកនៅគ្រប់គ្រងនៅតំបន់យើងនេះ ។

ធានី ៖ ហេតុអីបានជាអញ្ចឹង?

គុណ ៖ ខ្ញុំមិនអាចដឹងបាន មិនអាចដឹងបាន ថាតើហេតុអីបានជាគេយកតំបន់ស្រុកត្រាំកក់ តាមពិតទៅខ្ញុំយល់ឃើញអញ្ចេះ ព្រោះតំបន់ត្រាំកក់ហ្នឹង វាតំបន់ដីវិរមៀលហ្នឹងគឺតំបន់ខ្មែរតស៊ូអញ្ចឹងប្រហែលជាអ្នកអស់ហ្នឹងចាប់ផ្ដើមតស៊ូចាស់ឆ្នាំចាស់ខែជាងគេ គេឲ្យចាត់តាំងអ្នកអស់ហ្នឹងមកស្រុកគិរីវង់នេះ មិនអាចយកអ្នកគិរីវង់មកគ្រប់គ្រងគិរីវង់ហ្នឹងទេ ។

ធានី ៖ ចុះលោកគ្រូធ្លាប់ធ្វើជាជាង តើលោកគ្រូធ្លាប់ឃើញលិខិតឬក៏ជាសៀវភៅ ឬក៏ជាឯកសារស្អីនៅកន្លែងខ្មែរក្រហមទេ?

គុណ ៖ មិនដែលឃើញឯកសារទេ ឯកសារហ្នឹងមិនដែលបានឃើញទេ ។

ធានី ៖ ចុះលោកគ្រូដែលធ្លាប់ស្គាល់ឈ្មោះមីងអួនទេ?

គុណ ៖ មីងអួន?

ធានី ៖ កាលសម័យហ្នឹងគេហៅឈ្មោះមីងអួន?

គុណ ៖ ឈ្មោះ អួន មានតែប្រុស ។

ធានី ៖ អត់មានស្រីទេ?

គុណ ៖ បាទ!

ប្រពន្ធ ៖ អួន ហ្នឹងគេប្រធានកងពួកខ្ញុំ កងដូចថាម៉ែឪហ្នឹងពាក់ព័ន្ធហ្នឹង អាហ្នឹងគេខាងប្រធានកង តែអួន ហ្នឹងគេមិនមែននៅស្រុកគិរីវង់ទេ គេនៅដូចជាត្រាំកក់អីនោះ គេមកត្រួតនៅខាងគិរីវង់ តែកាលជំនាន់កងចល័ត ។

គុណ ៖ ព្រោះកាលហ្នឹងប៉ុនខ្ញុំ ហើយខ្ញុំអត់ដែលស្គាល់គ្នាផងហ្នឹង នៅចម្ងាយហ្នឹងអត់ដែលស្គាល់ទេ ។

ប្រពន្ធៈ ឈ្មោះ អួន កាលជំនាន់ហ្នឹងគេមិនមែននៅស្រុកគិរីវង់ទេ គេនៅស្រុកត្រាំកក់អីណាណី គេមកនៅត្រួតហ្នឹង គេដូចថាគេមកធ្វើប្រធានកង ដូចថាអ្នកពាក់ព័ន្ធម៉ែឪដូចកាលជំនាន់អាពតគេយកទោសម្ដាប់ចោលហ្នឹងគេយកដាក់មួយដុំហើយ ហើយដូចខ្ញុំអញ្ចឹងគេយកដាក់មួយដុំហើយ មិនមែននៅជាមួយប្រជាជនទេ សុទ្ធតែដូចថាគេបំរុងយកទៅវៃចោលទៀត ។

លក្ខិណា ៖ អញ្ចឹងលោកគ្រូដែលបានមើលតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមទេ?

គុណ ៖ ខ្ញុំមើលតាមទូរទស្សន៍ ។

លក្ខិណា ៖ ហើយលោកគ្រូមានដឹងថាមេដឹកនាំណាខ្លះដែលគេឃុំឃាំង ហើយមេដឹកនាំណាខ្លះគេកាត់ទោស

គុណ ៖ ខ្ញុំដឹងគឺ៥នាក់ ។

លក្ខិណា ៖ ៥នាក់ហ្នឹងឈ្មោះអីខ្លះ?

គុណ ៖ ទី១គឺខៀវ សំផន, អៀង សារី, អៀង ធារិទ្ធ, សុន សេន ហើយនឹងតាកាំងហ្កេកអ៊ាវ ។

លក្ខិណា ៖ សុន សេន អត់មានទេ សុន សេន ស្លាប់ហើយ គឺមាននួន ជា ។

គុណ ៖ ហ្នឹងហើយនួន ជា ។

ធានី ៖ អញ្ចឹងលោកគ្រូបានមើលទូរទស្សន៍ញឹកញាប់ដែរ?

គុណ ៖ បាទ! បានមើលញឹកដែរ ។

ធានី ៖ អញ្ចឹងលោកគ្រូមានដឹងថារាល់ថ្ងៃនេះគេកាត់ទោសអ្នកណាហើយខ្លះ ហើយនៅអ្នកណាខ្លះ?

គុណ ៖ ឥឡូវនេះការកាត់ទោសនេះគឺតា កាំងហ្កេកអ៊ាវ ហៅ ឌុច ហ្នឹង តែមិនទាន់សម្រេចថាដាក់គុកឬត្រូវសម្លាប់ទេ អាហ្នឹងតាមដែលខ្ញុំដឹង ប៉ុន្តែឥឡូវពុថាអូនឲ្យសៀវភៅនេះ អាស្អី?

លក្ខិណា ៖ លេខ០០២?

គុណ ៖ បាទ! សំនុំរឿង០០២ហ្នឹង អាហ្នឹងអត់ទាន់ដឹងទេ ។

លក្ខិណា ៖ អញ្ចឹងខ្ញុំប្រាប់ដំណឹងមួយថា ថ្ងៃ២៦នេះគេប្រកាសសាលក្រមរបស់ ឌុច ។

គុណ ៖ បាទ! អាហ្នឹងខ្ញុំដឹងខែ៧ហ្នឹងហើយ ។

លក្ខិណា ៖ អញ្ចឹងអាហ្នឹងយើងដឹងទាំងអស់គ្នាហើយ ថាគេកាត់ទោសឬក៏ដោះលែងអញ្ចឹងណាំលោកគ្រូ ហើយអញ្ចឹងលោកគ្រូដែលពុការសុំទោសរបស់ឌុចទេលោកគ្រូ?

គុណ ៖ បានពុ ។

លក្ខិណា ៖ បានពុដែរ?

គុណ ៖ បាទ! ទី១តាមរយៈការអានកាសែត ។

លក្ខិណា ៖ ពេល ឌុច សុំទោសអញ្ចឹងលោកគ្រូមានអារម្មណ៍យ៉ាងម៉េចដែរ?

គុណ ៖ ខ្ញុំថាចំពោះការប្រព្រឹត្តរបស់ ឌុច នេះ បើសិនណាជាស្អាតស្អំវាចេះតែបានហើយ តែអ្នកស្លាប់គឺស្លាប់បាត់ទៅហើយ តែអ្នកមានកំហឹងពុះពន្លាំងមែនទែន គេចង់ថាឲ្យដាក់គាត់មួយជីវិត ប៉ុន្តែទោសដូចថាត្រូវលើកលែងទេ ខ្ញុំថាអត់ មិនអាចលើកលែងព្រោះខ្មែរយើងនៅ

ប្រទេសកម្ពុជាយើងច្បាប់រដ្ឋធម្មនុញ្ញមិនឲ្យសម្លាប់ទេ តែបើសិនជាសម្លាប់ទោសដូចត្រូវស្លាប់ ប៉ុន្តែគ្រាន់ថាកំហុសនេះគឺថា បើយុំឃាំងគាត់ ធ្វើម៉េចឲ្យគាត់ស្លាប់ទៅតាមកម្មរបស់គាត់ចុះ អាហ្នឹងល្អហ្នង បើថាលើកលែងខ្ញុំថាមិនគួរទេ ព្រោះថាអំពើរដែលគាត់ធ្វើនេះ ឥឡូវសព្វថ្ងៃគាត់ទទួលកំហុសគាត់លាតត្រដាងហើយ ហើយគាត់សុំទោសប្រជាជនថាគាត់បានធ្វើមែន ឥឡូវគាត់សុំទោស ហើយគាត់យកពាក្យប៉ុណ្ណឹងមកសង ខ្ញុំថាក្រែងលោវាមិនរួចឬយ៉ាងម៉េច ប៉ុន្តែចំពោះផ្នែកពុទ្ធសាសនាខ្ញុំបានបួស ខ្ញុំបានរៀនណា៎ ពៀរកុំឲ្យចងពៀរ ពៀររំងាប់ដោយការមិនចងពៀរ ។

លក្ខិណា ៖ អញ្ចឹងលោកគ្រូមានដឹងពីលើ ពីការគាត់ស្នើរសុំឲ្យគាត់រួចខ្លួនទេ?

គុណ ៖ អាហ្នឹងចុះទស្សនាវដ្តីមាន ។

លក្ខិណា ៖ ទស្សនាវដ្តីមានដែរ?

គុណ ៖ អាស៎! កាសែត ។

លក្ខិណា ៖ ហើយដល់ពេលលោកគ្រូឮអញ្ចឹង លោកគ្រូមានអារម្មណ៍យ៉ាងម៉េចដែរ?

គុណ ៖ ខ្ញុំដល់ពេលឮអញ្ចឹងដូចជាថា អំពើរដែលគាត់ធ្វើហ្នឹងគឺគាត់ទទួលដឹងឮហើយ ដល់ហើយគាត់សុំរួចខ្លួនអញ្ចឹង វាដូចថាគាត់អ្នកចេះដឹង ហាក់ដូចជាមិនទំនងដែរ វាមិនត្រូវដែរ ។

លក្ខិណា ៖ អញ្ចឹងលោកគ្រូយល់ថា គួរតែជាប់ទោសអស់មួយជីវិត ឬក៏ស្លាប់ទៅតាមដំណើររបស់គាត់បានត្រឹមត្រូវ?

គុណ ៖ អាហ្នឹងខ្ញុំយល់ឃើញថាអញ្ចឹង ឲ្យគាត់ស្លាប់ទៅតាមហ្នឹង ។

លក្ខិណា ៖ ហើយចុះលោកគ្រូឮហើយថាឌុច ហ្នឹងគាត់ទទួលខុសត្រូវ គាត់ទទួលសារភាពកំហុស ចុះមេ៤នាក់ផ្សេងទៀត មេដឹកនាំ៤នាក់ផ្សេងទៀតគាត់ឆ្លើយថាគាត់អត់ដឹង អត់ទទួលស្គាល់កំហុស ហើយពូគិតថា តើពូគិតថាគាត់អាចនឹងសុំទោសដូច ឌុច ទេ?

គុណ ៖ ខ្ញុំជឿថាការឆ្លើយរបស់គាត់ ដែលគាត់ថាគាត់មិនដឹងនេះ អានេះស្រេចទៅលើតុលាការស្រេចទៅលើការកាត់ទោសរបស់តុលាការ ក្រែងលោចៅក្រមស៊ើបអង្កេតអីដឹងពីប្រវត្តរបស់អ្នកទាំង៤នាក់ហ្នឹងជាងខ្ញុំ ព្រោះគេតាមដានណា៎ អញ្ចឹងបើគាត់សុំទោសអញ្ចឹងហើយគាត់ជាថ្នាក់ដឹកនាំប្រទេស ខ្ញុំថាដូចជាមិនសមដែរ ។

លក្ខិណា ៖ មិនសមនឹងអត់ដឹងឬក៏ម៉េច?

គុណ ៖ មិនសមនឹងអត់ដឹង ខ្ញុំមិនជឿថា ព្រោះប៉ុល ពតនេះ ខ្ញុំដឹងថាបើកាលណាវារបបយើងគឺទុកអ្នកចេះគឺអ្នកចេះត្រូវមានការពិចារណា អញ្ចឹងគំនិតអ្នកទាំងអស់ហ្នឹងកុំថាមិនដឹងថា

ប្រជាជនទទួលរងទុកវេទនា ត្រូវទទួលស្គាល់ដឹងពុថារបបដែលអញបានធ្វើធំហ្នឹងគឺប្រជាជនលំបាក មិនមែនគាត់ថាគាត់មិនដឹងទេ ហើយកាលដែលគាត់សុំរួចខ្លួន សុំទទួលកំហុសថាកុំឲ្យដាក់ទោសគាត់ អាហ្នឹងខ្ញុំស្រេចលើតុលាការ ប៉ុន្តែបើបញ្ជាក់ទៅវាអត់ត្រឹមត្រូវ ។

លក្ខិណា ៖ ចុះនៅពេលដែលពូបានតាមដានតុលាការ ឃើញគេកាត់ទោសអ៊ីអញ្ចឹង ពូអស់ចិត្តនូវនៅរឿងរ៉ាវដែលពូឆ្ងល់កាត់សម័យហ្នឹង ពូឈឺចាប់អីអញ្ចឹង?

គុណ ៖ ចំពោះការកាត់ទោសនេះ បើមតិរបស់ខ្ញុំយល់ ខ្ញុំឃើញថាជាគំរូដល់ល្អមួយដែរដើម្បីកុំឲ្យថ្នាក់ដឹកនាំក្រោយធ្វើយកគំរូតាមក្រុមដឹកនាំរបបហ្នឹង អាហ្នឹងខ្ញុំនឹកឃើញ ហើយអាហ្នឹងក៏ជារឿងសំខាន់មួយដែរ ព្រោះថាខ្ញុំមិនដែលជួបមិនដែលប្រទះដែរ អានេះខ្ញុំបានជួបឃើញមានអង្គការសហប្រជាជាតិ អង្គការអន្តជាតិអីគេទទួលដឹងពុ គេទទួលស្គាល់ ហើយក៏ជាមោទនៈភាពរបស់ខ្មែរយើងមួយដែរ ដោយថារបបយើង របបប្រល័យពូជសាសន៍ស្ថិតនៅក្នុងប្រទេសកម្ពុជាយើង ហើយក្រោយមករំដោះមកមាននឹកឃើញថា ស្រាវជ្រាវយកអ្នកហ្នឹងមកកាត់ទោសអី ក្រោយមកអង្គការសហប្រជាជាតិបានរៀបចំតុលាការកាត់ទោសខ្មែរក្រហមហ្នឹង ដូចខ្ញុំថាអញ្ចឹង ខ្ញុំសូមសរសើរតុលាការដែលខំរកយុត្តិធម៌ឲ្យប្រជាជនដែលរងគ្រោះសម័យហ្នឹង ។

លក្ខិណា ៖ អញ្ចឹងសហព្រះរាជអាជ្ញារគាត់បានស្នើរសុំឲ្យ ឌុច ហ្នឹងជាប់ទោស៤០ឆ្នាំ ពូយល់ថាការកាត់ទោសហ្នឹងយ៉ាងម៉េចដែរ ៤០ឆ្នាំហ្នឹងតិច ច្រើន ឬល្អម?

គុណ ៖ អានេះខ្ញុំនឹកឃើញ ខ្ញុំមើលតាមទូរទស្សន៍ ហើយនឹងមើលទស្សនាវដ្ដីឃើញរូបឌុចហៅកាំងហ្កេកអ៊ាវ ខ្ញុំថាបើទោសគាត់ត្រូវ៤០ឆ្នាំខ្ញុំថាប្រហែលមិនដល់៤០ឆ្នាំទេ ។

លក្ខិណា ៖ តែលោកគ្រូគិតថាទោសហ្នឹងសមនឹងគិតគួរហើយឬក៏នៅតិចទេ?

គុណ ៖ អានេះខ្ញុំមិនចំណាយទៅលើចិត្ត ដូចខ្ញុំមានការពិចារណាដែរថា ស្រេចទៅលើតុលាការកាត់ក្ដីថា ទោសដែលត្រូវជាប់គុកប៉ុន្មានគឺតុលាការធ្វើតាមដំណើរ ។

លក្ខិណា ៖ ហើយចុះពូមានដឹងពុថា រាល់ថ្ងៃហ្នឹងតុលាការគេបានចោទប្រកាន់ពីទោសប្រល័យពូជសាសន៍មេដឹកនាំទាំង៤នាក់ហ្នឹងទៀតទេ?

គុណ ៖ សព្វថ្ងៃនេះខ្ញុំការតាមដានហ្នឹងខ្ញុំមិននេះដែរ តែតាមដែលខ្ញុំពុទៅឲ្យតែសម្រេចកាំងហ្កេកអ៊ាវហើយ ហើយមួយទៀតចង់ស្រាវជ្រាវរកអ្នកដឹកនាំផ្សេងទៀត ។

លក្ខិណា ៖ អ្នកដឹកនាំផ្សេងទៀត?

គុណ ៖ អ្នកដឹកនាំផ្សេងទៀត ប៉ុន្តែដោយរាជរដ្ឋាភិបាលសព្វថ្ងៃនឹកឃើញថា បើសិនណាជាធ្វើអញ្ចឹងខ្លាចធ្វើឲ្យប្រទេសខ្មែរហ្នឹងមានការជ្រួលច្របល់ អញ្ចឹងឥឡូវនៅ៤នាក់ចុងក្រោយនេះ ខ្ញុំមិនទាន់បានឮថាត្រូវលើកយកមកជំនុំជម្រះនៅពេលណាទេ ខ្ញុំអត់ទាន់បានដឹងទេ ។

លក្ខិណា ៖ លោកគ្រូ បើសិនជាតុលាការហ្នឹងគេចោទប្រកាន់ពួកគាត់ពីទោសប្រល័យពូជសាសន៍ លោកគ្រូគិតថាជាការល្អឬក៏ខ្ជះខ្ជាយពេលវេលា?

គុណ ៖ អានេះបើសិនណាជាយើងនិយាយពីការគ្រប់គ្រងរបស់គាត់ ហើយគាត់មិនទទួលស្គាល់ថាគាត់ជាអ្នកគ្រប់គ្រងរបបហ្នឹង គាត់មិនមែនជាអ្នកប្រល័យពូជសាសន៍ ខ្ញុំថាវាត្រូវតែគាត់ទទួលដឹងឮដែរ ទទួលស្គាល់ដឹងឮម៉េច ព្រោះកាំងហ្គេកអ៊ាវ ដែលនៅគ្រប់គ្រងកន្លែងគុកហ្នឹងក៏មិនមែនកាំងហ្គេកអ៊ាវហ្នឹងធ្វើធំដែរ គឺអ្នកអស់ហ្នឹងឯងអ្នកឲ្យកាំងហ្គេកអ៊ាវមកត្រួតត្រាកន្លែងហ្នឹង ឲ្យនៅមើលការខុសត្រូវកន្លែងហ្នឹង គ្រប់គ្រងអាអ្នកដែល.. អ្នកនៅគុកទួលស្លែងហ្នឹងមិនធម្មតាទេបើតាមខ្ញុំស្តាប់ទៅ ហើយខ្ញុំរៀនចេះដឹងដែរគឺសុទ្ធតែអ្នកចេះទាំងអស់ សុទ្ធតែបញ្ញាវ័ន្តទាំងអស់ អញ្ចឹងវាសម្លាប់បញ្ញាវ័ន្តទាំងអស់នោះហើយមិនមែនគំនិតកាំងហ្គេកអ៊ាវទេ ពិតជាមិនមែនគំនិតកាំងហ្គេកអ៊ាវទេ ។

លក្ខិណា ៖ ចុះពូមានដឹងថាពាក្យប្រល័យពូជសាសន៍ហ្នឹងមានន័យថាម៉េចទេ?

គុណ ៖ ពាក្យថាប្រល័យពូជសាសន៍ ពាក្យថាប្រល័យគឺប្រហារ អញ្ចឹងប្រល័យពូជសាសន៍គឺធ្វើយ៉ាងណាឲ្យបាត់ពូជសាសន៍ខ្មែរយើង ។

លក្ខិណា ៖ ចុះពូមានដឹងមូលហេតុអីបានគេចង់បំបាត់ពូជសាសន៍ខ្មែរយើងហ្នឹងទេ?

គុណ ៖ នេះបើតាមខ្ញុំពិចារណា គឺចង់បំបាត់ពូជសាសន៍ខ្មែរព្រោះខ្មែរយើងគឺ ប្រទេសកម្ពុជាយើងគឺសុវណ្ណភូមិ ជាភូមិមាស អញ្ចឹងសូម្បីតែអ្នកណាក៏គេចង់បានមាសដែរ យើងនិយាយពីប្រជាជនវិញអ្នកណាធ្វើចិនគេស្រលាញ់មាស យួនក៏ស្រលាញ់មាស អាមេរិចកាំងក៏ស្រលាញ់មាស អញ្ចឹងខ្មែរយើងគឺលូកដៃគ្រប់ អាមេរិច បារាំង ចិន យួន សៀម ចុះហេតុអីខ្មែរប៉ុណ្ណឹងគេចង់សម្លៀមម្លេះ អញ្ចឹងបើបាត់ពូជសាសន៍ហ្នឹងទៅគឺវាលែងទឹកដី ទឹកដីហ្នឹងជាទឹកដីមួយដំបូងដែលគេចង់បាន ហើយមកធ្វើអញ្ចឹង ហើយបើនិយាយពីប្រវត្តិថាដូចវៀតណាមនេះអីហ្នឹងគ្មានទឹកដីសោះ ហើយសព្វថ្ងៃគេមានទឹកដី គេមានប្រទេស ហ្នឹងនិយាយពីប្រវត្តិ អាហ្នឹងខ្ញុំធ្លាប់រៀនប្រវត្តិសាស្រ្ត អាហ្នឹងយើងប្រវត្តិសាស្រ្តជំនាន់ហ្នឹង អញ្ចឹងខ្មែរយើងខាងជើងទល់នឹងប្រទេសចិនទន្លេវៀតណាម ហើយខាងត្បូងទន្លេសុងកុងជាប់ក្នុងប្រវត្តិសាស្រ្ត អញ្ចឹងខ្មែរយើងមុនធំ គឺមហានគរ ឥឡូវលែងមហាហើយ វាទៅជា

តូចហើយលែងមហាហើយ អញ្ចឹងខ្ញុំនឹកឃើញថាបានជាចង់បំបាត់ហ្នឹងដូចថា ខ្មែរយើងហ្នឹងគឺជាប្រទេសមួយសំបូរ ប្រទេសមួយរុងរឿង មើលឃើញជាអច្ឆិរិយៈវត្ថុ សព្វថ្ងៃនេះយើងឃើញហើយប្រទេសណានៅលើពិភពលោកមិនអាចកសាងនគរបានទេ ប្រវត្តិសាស្ត្រខ្មែរយើង អញ្ចឹងខ្មែរយើងរុងរឿងដែរ អញ្ចឹងបើបំបាត់ពូជសាស្ត្រខ្មែរទៅគឺមកកាន់កាប់ទឹកដី សព្វថ្ងៃនេះគឺគេចង់បានទឹកដីគ្រប់គ្នាទាំងអស់ អញ្ចឹងបានខ្ញុំថាព្រោះតែគេចង់បានហ្នឹងបានគេមិនចង់ឲ្យមានខ្មែរ កុំឲ្យពូពាក្យថាខ្មែរហ្នឹង ពូតែចិន ពូតែយួន ពូតែសៀម ពូអាមេរិចអញ្ចឹងទៅ អញ្ចឹងខ្មែរត្រូវរលាយហើយ អញ្ចឹងពាក្យថាប្រល័យពូជសាសន៍បំបាត់ពូជសាសន៍ហើយ គឺបំបាត់ពូជខ្មែរហ្នឹងតែម្តង ។

លក្ខិណា ៖ ចុះពូ ពូយល់ថាការបង្កើតតុលាការមកហ្នឹងពូពេញចិត្តដែរទេ?

គុណ ៖ បាទ! ប្រទេសត្រូវមានច្បាប់ អញ្ចឹងកាលណាមានច្បាប់យើងត្រូវតែពេញចិត្ត ត្រូវតែស្រលាញ់ពេញចិត្ត ។

លក្ខិណា ៖ ចុះតុលាការហ្នឹងអាចរកយុត្តិធម៌ជូនពូបានទេ?

គុណ ៖ អានេះចំពោះមតិរបស់ខ្ញុំជាប្រជាជនសាម័ញ្ញមួយរូប ហើយមានការចេះដឹងតិចតួច ហើយខ្ញុំចេះតែស្តាប់ការកាត់ទោសឲ្យ ឌុច ចំពោះតុលាការនេះខ្ញុំថាគឺសំខាន់ខ្លាំងណាស់ ប្រពៃណាស់ ព្រោះថាគេទទួលដឹងឬពេញមួយពិភពលោក ទាំងអង្គការសហប្រជាជាតិគេទទួលស្គាល់ដឹងពូនូវតុលាការកាត់ទោសឲ្យ ឌុច នេះ ។

លក្ខិណា ៖ ចុះពូ ដូចថាមេដឹកនាំពូដឹងហើយថាគាត់វាងចាស់ហើយឈឺអញ្ចឹង ហើយគ្រាន់តែកាំងហ្គេកអ៊ាវចំណាយពេលវេលាស៊ើបអង្កេតហើយនឹងកាត់ក្តីហ្នឹងវាជិត២ឆ្នាំហើយ ហើយចុះបើមេដឹកនាំផ្សេងទៀតដែលគេកាត់ក្តីអត់សព្វអញ្ចឹង អ្នកដែលស្លាប់គឺគេលែងកាត់ទោសហើយអញ្ចឹងខបមាស្មាទោសចុះ បើគាត់អាចទៅមុនអញ្ចឹងព្រោះគាត់ឈឺចាស់អញ្ចឹង ពូគិតថាបើសិនតុលាការហ្នឹងកាត់ទោសអត់បានសម្រេចអញ្ចឹង នៅតែផ្តល់យុត្តិធម៌ជូនពូដដែល?

គុណ ៖ អានេះបើសិនណាជា ឧទាហរណ៍ថាឥឡូវយើងចំណាយពេល ខ្ញុំជឿជាក់ថាការស៊ើបអង្កេតរបស់តុលាការគឺខ្ញុំថាដឹងហើយអស់ហើយ គេតាមដានមិនមែនស៊ើបអង្កេតចាប់បើកតុលាការហ្នឹងហើយ ហើយបានស៊ើបអង្កេតក្រោយ បើតាមខ្ញុំអានសៀវភៅ ដូចលោកឆាំង យុ អីហ្នឹង កាសែតនានាៗគឺគេតាមដានហើយ ហើយម្យ៉ាងទៀតក៏មានប្រទេសមួយចំនួនដែលធ្លាប់មានធ្វីការប្រល័យពូជសាសន៍របស់ខ្លួនដែលសម្លាប់ពូជសាសន៍ខ្លួនឯងដែរគេបង្កើតតុលាការកាត់ទោស អញ្ចឹងគេដឹងប្រវត្តិអស់ហ្នឹងហើយ ហើយគេតាមដានស្រាវ

ជ្រាវរកហេតុផលរបស់អ្នកដឹកនាំ ហើយខ្ញុំជឿថាបានជាគេបង្កើតតុលាការហ្នឹងឡើង ហើយសព្វថ្ងៃនេះបើសិនណាជាយើង ប្អូនសួរខ្ញុំថាយើងចំណាយពេលវេលាស៊ើបអង្កេតការអ្នកដែលនៅរស់នេះ ខ្ញុំជឿថាគេមិនចំណាយពេលប៉ុន្មានទេ ព្រោះរឿងហ្នឹងដឹងហើយ ខ្ញុំជឿថាគេដឹងហើយអស់ ហេតុអីបានជាខ្ញុំថាដឹងហើយ ព្រោះថាដូច ឌុច អញ្ចឹងខ្វះអី អ្នកអំណះអំណាង អ្នកដែលទទួលរងគ្រោះ មានបង មានប្ដី មានកូនដែលខ្ញុំមើលទូរទស្សន៍ ហើយនឹងអានកាសែត អញ្ចឹង ឌុច គាត់ទទួលបញ្ហាពីនោះមកដែរ ហើយគាត់ចាស់ៗហើយ បើយើងថាមិនចំណាយពេលវេលា ឃើញថាខាតពេលវេលា អញ្ចឹងយើងទុកឲ្យគាត់ធ្វើការតាមចំណេះ នឹងទៅតាមអាយុកាលរបស់គាត់ ហើយគាត់រួចខ្លួនខ្ញុំថាអានេះស្រេចទៅលើតុលាការទៅ ខ្ញុំមិនដឹងដែរ ហើយយើងជាប្រជាពលរដ្ឋមួយរូប បើសិនណាជាយើងនៅតែថាត្រូវតែសម្លាប់គាត់ ត្រូវតែដាក់គុកគាត់ ទោះមិនសម្លាប់ក៏គាត់ត្រូវតែស្លាប់ ។

លក្ខិណា ៈ ចុះពូ តុលាការបង្កើតមកហ្នឹងមានផលប្រយោជន៍ដល់កូនចៅយើងជំនាន់ក្រោយទេ?

គុណ ៈ ខ្ញុំនឹកឃើញថាតុលាការបង្កើតហ្នឹងគឺសំខាន់ណាស់អូន បើមិនសំខាន់មិនចំណាយរាប់លានគ្រាន់ស្ទុះដំណើរការកាត់ទោសកាំងហ្កេកអ៊ាវដោយសារគ្មានថវិការ អញ្ចឹងបុគ្គលិកដែលនៅបម្រើការងារក្នុងតុលាការកាត់ទោសខ្មែរក្រហមមិនធម្មតាទេអូន ច្រើនហើយត្រូវចំណាយច្រើនទៀត ព្រោះមានមេធាវីបរទេសផង អញ្ចឹងមេធាវីមួយៗប្រាក់មិនតិចណា៎ ចំណាយពេលវេលា អញ្ចឹងដើម្បីឲ្យតុលាការនេះកើតជារូបរាងឡើងគឺចង់ឲ្យកូនចៅយើងជំនាន់ក្រោយ ក្រែងលោកូនចៅណាមួយក្លាយទៅជាអ្នកដឹកនាំ ឬក៏អ្នកដឹកនាំបច្ចុប្បន្នមានគំនិតឆ្កួតយល់ដូចប៉ុល ពត តុលាការនេះគឺអាចយកទោសអ្នកហ្នឹងបាន ។

លក្ខិណា ៈ អញ្ចឹងចុងក្រោយនេះពូមានអីចង់បន្ថែមទេ?

គុណ ៈ ជាចុងក្រោយនេះខ្ញុំគ្មានអីទេ ក្រោយពេលដែលអូនបានមកជួបសម្ភាសន៍ជាមួយខ្ញុំបាទ ខ្ញុំមានសេចក្ដីត្រេកអរជារលីក ដោយអូនទាំងពីរបានមកសម្ភាសន៍ខ្ញុំនេះគឺចង់បញ្ជាក់អំពីរតុលាការកាត់ទោសឲ្យខ្មែរក្រហមគឺខ្ញុំមានសេចក្ដីរំភើបដែរ ដោយខ្ញុំមានទឹកចិត្តសប្បាយរីករាយដោយតុលាការនេះអាចរកយុត្តិធម៌ឲ្យកូនខ្មែរយើង ឲ្យជនរងគ្រោះរបស់យើងមានការអស់ចិត្ត ហើយនឹងជឿជាក់ទៅលើអង្គការទៅថ្ងៃអនាគតច្បាស់ជារកយុត្តិធម៌ឲ្យប្រជាពលរដ្ឋចំពោះទង្វើអ្នកដឹកនាំណាមួយធ្វើដូចប៉ុល ពត ខ្ញុំមានតែប៉ុណ្ណឹងទេ សូមអរគុណ ។

លក្ខិណា ៖ អញ្ចឹងចុងក្រោយនេះសូមអរគុណពូច្រើនដែលបានចំណាយពេលវេលាឲ្យពួកខ្ញុំសម្ភាសន៍ពូ អញ្ចឹងអរគុណច្រើនពូ ។

គុណ ៖ បាទ!

«ចប់»